# ទិដ្ឋភាពទន្លេ
# នៅក្នុងការផ្លាស់ប្ដូរ

# Riverscapes IN FLUX

ស-សបាសាក់ SA SA BASSAC

GOETHE INSTITUT

# ទិដ្ឋភាពទន្លេនៅក្នុងការផ្លាស់ប្តូរ

លីម សុខចាន់លីណា, លួងហ៊ូ ទ្រីញ, ផាន់ថៅ ង្វូយិន, ស៊ូធីរ៉ាត់ ស៊ូប៉ាប៉ារិនយ៉ា, ថន សុខ, វុធ លីណូ

**ថ្ងៃ ១៨ តុលា - ១១ វិច្ឆិកា ២០១២**
**សម្ពោធ ថ្ងៃ១៨ តុលា ម៉ោង ៦:០០-៨:០០ យប់**
**នៅ ស-សបាសាក់**
**ផ្ទះលេខ១៨ ជាន់ទី២ ផ្លូវសុធារស ភ្នំពេញ កម្ពុជា**

<u>កម្មវិធីពាក់ព័ន្ធ៖</u>

**ថ្ងៃពុធ ៣១ តុលា ម៉ោង ៧ យប់**
វេទិកាពិភាក្សា នៅមេត្តាហៅស៍៖ ភាពច្នៃប្រឌិតអំពីទន្លេកម្ពុជាជាមួយ សាន វណ្ណារី, ស្សែលប៊ី ដយយ៉ល, ជុំ សុភា

**ថ្ងៃសៅរ៍ ៣ វិច្ឆិកា ម៉ោង ៧ យប់**
ការបញ្ចាំងខ្សែភាពយន្ត នៅមេត្តាហៅស៍៖ កម្រងខ្សែភាពយន្តឯកសារអំពីបឹងទន្លេសាប និងទន្លេមេគង្គ

**ថ្ងៃសុក្រ ៩ វិច្ឆិកា ម៉ោង ៦ យប់**
កិច្ចពិភាក្សារបស់សិល្បករ នៅស-សបាសាក់ សន្ទនាជាមួយអ្នករៀបចំពិព័រណ៍ អេរិន ឃ្លីសិន

រាល់កម្មវិធីទាំងអស់រៀបចំជាភាសាខ្មែរ និងអង់គ្លេស និងអាចចូលរួមដោយឥតគិតថ្លៃ
មេត្តាហៅស៍ ផ្ទះលេខ៣៧ ផ្លូវសុធារស

# Riverscapes IN FLUX

Lim Sokchanlina, Luong Hue Trinh, Phan Thao Nguyen, Sutthirat Supaparinya, Than Sok, Vuth Lyno

**18 October - 11 November 2012**
**Opening 18 October 6:00 - 8:00pm**
**SA SA BASSAC**
**#18 2nd Floor, Sothearos Blvd**
**Phnom Penh, Cambodia**

<u>Related events:</u>

**Wednesday 31 October 7pm**
Panel at Meta House: Creatives on Cambodia's Rivers with San Vannary, Shelby Doyle, Chum Sophea

**Saturday 3 November 7pm**
Films at Meta House: Line-up of documentaries focusing on the Mekong and Tonle Sap Rivers

**Friday 9 November 6pm**
Artists' Talks at SA SA BASSAC, in conversation with curator Erin Gleeson

All events are free and in Khmer + English
Meta House is located at #37 Sothearos Blvd

# ទិដ្ឋភាពទន្លេនៅក្នុងការផ្លាស់ប្តូរ គម្រោងសិល្បៈអន្តរជាតិនៃអេកូឡូហ្ស៊ីនិងវប្បធម៌ អំពីទិដ្ឋភាពទន្លេនៅអាស៊ីអាគ្នេយ៍

## អាល់ម៉ូត ម៉ុយឃឺហ្សលីត
## នាយក នៃវិទ្យាស្ថាន Goethe-Institut វៀតណាម

ទន្លេក្រហម និងទន្លេមេគង្គ ទន្លេអ៊ីរ៉ាវ៉ាឌី និងទន្លេ ចៅផាយ៉ា។ ទាំងនេះជាទន្លេធំៗសំខាន់ៗនៅអាស៊ីអាគ្នេយ៍ ដែលធ្វើអោយតំបន់នេះមានលក្ខណៈពិសេសខុសពីតំបន់ដទៃទៀតនៅក្នុងពិភពលោក។ ទន្លេទាំងនេះគឺជាខ្សែជីវិត ផ្លូវដឹកជញ្ជូន ផ្លូវសេដ្ឋកិច្ច និងប្រព័ន្ធបរិស្ថានដ៏សំខាន់។ ផ្លូវទឹកជានាបាននូវផលិតកម្មស្បៀង និងការផ្គត់ផ្គង់ថាមពល មិនត្រឹមតែសម្រាប់ប្រជាជនក្នុងស្រុកប៉ុណ្ណោះទេ តែជាញឹកញាប់ថែមទាំងសម្រាប់តំបន់ទាំងមូលផងដែរ។ ប៉ុន្តែ ការរុនរានផ្នែកសេដ្ឋកិច្ចមកលើដងទន្លេ និងផលវិបាកនៃការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមដ៏ខ្លាំងក្លា បានបង្កអោយមានការខូចខាតយូរអង្វែងដល់ដងទន្លេទាំងនេះ។

លើសពីនេះ ឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុ គឺជាការគំរាមកំហែងមួយបន្ថែមទៀតមកលើប្រព័ន្ធបរិស្ថានដែលកំពុងរងគ្រោះរួចទៅហើយនេះ។ ភាពប្រែប្រួលដ៏សម្បើមរវាងទឹកជំនន់ និង គ្រោះរាំងស្ងួត បានគំរាមបំផ្លាញដល់ជម្រកនៅតាមដងទន្លេ និងជីវិតមនុស្សរាប់លាននាក់។

គម្រោងសិល្បៈទិដ្ឋភាពទន្លេនៅក្នុងការផ្លាស់ប្តូរដែលបានផ្តួចផ្តើមនិងរៀបចំដោយវិទ្យាស្ថាន Goethe-Institut ប្រចាំនៅប្រទេសវៀតណាមខិតខំបង្កើតកិច្ចពិភាក្សាមួយអំពីបញ្ហាអេកូឡូហ្ស៊ី ដ៏សំខាន់នេះ នៅក្នុងបរិបទថ្មីមួយ។ វិទ្យាស្ថាន Goethe-Institut បានអញ្ជើញសិល្បករក្មេងៗពីប្រទេសវៀតណាម ថៃ កម្ពុជា មីយ៉ាន់ម៉ា ឥណ្ឌូនេស៊ី និង ហ្វីលីពីន ដើម្បីឆ្លុះបញ្ចាំងតាមរយៈស្នាដៃរបស់ពួកគេអំពីការផ្លាស់ប្តូរផ្នែកអេកូឡូហ្ស៊ី ក៏ដូចជាផ្នែកសេដ្ឋកិច្ចសង្គម និងវប្បធម៌ ដែលទន្លេនៅតាមបណ្តាប្រទេសទាំងនេះកំពុងជួបប្រទះ។

ជាមួយការគាំទ្រពីអ្នកជំនាញរៀបចំកម្មវិធីសិល្បៈមួយក្រុម ស្នាដៃសិល្បៈចំនួន ១៧ ត្រូវបានបង្កើតឡើង ក្នុងនោះមានការតម្លើងមីឌាចំរុះ (multi-media) និងស្នាដៃរូបថត ការតម្លើងវីដេអូ និងឧបករណ៍។ ពិព័រណ៍សិល្បៈដែលបានបើកសម្ពោធនៅទីក្រុងហាណូយ ធ្វើដំណើរទៅកាន់ទីក្រុងហូជីមិញ បាងកក ភ្នំពេញ ហ្សាកាតា និងម៉ានីល ដោយពាំនាំទៅជាមួយនូវការបញ្ចាំងខ្សែភាពយន្ត និងសកម្មភាពវប្បធម៌ និងអប់រំជាច្រើនផងដែរ។

តាមរយៈគម្រោងសិល្បៈនេះ វិទ្យាស្ថាន Goethe-Institut ចង់ចូលរួមចំណែកក្នុងការលើកកម្ពស់ការយល់ដឹងអំពីកេរ្តិ៍តំណែលអេកូឡូហ្ស៊ី និងវប្បធម៌ដ៏មានតម្លៃនៃដងទន្លេសំខាន់ៗ នៅអាស៊ីអាគ្នេយ៍។ សកម្មភាពគាំទ្រនានា និងជាពិសេស blog ពិព័រណ៍ blog.goethe.de/riverscapes នឹងផ្តល់នូវឱកាសសម្រាប់ការពិភាក្សាបន្ថែម។ យើងសង្ឃឹមថានឹងមានការផ្លាស់ប្តូរយោបល់យ៉ាងសកម្មរវាងសិល្បករនិងទស្សនិកជន ដែលបន្តជាហូរហែគ្មានព្រំដែន ហាក់ដូចជាទឹកទន្លេដូច្នោះដែរ។

# Riverscapes IN FLUX
## AN INTERNATIONAL ECO-CULTURAL ART PROJECT ON THE RIVER LANDSCAPES OF SOUTHEAST ASIA

Almuth Meyer-Zollitsch
Director, Goethe-Institut Vietnam

The Red River and the Mekong, the Irrawaddy and the Chao Phraya: Southeast Asia is characterized by major river landscapes like no other region in the world. They are lifelines and transport routes, economic roads and vital ecosystems. The waterways secure food production and energy supply not only for the local population but often for a vast region. However the economic exploitation of the rivers and the consequences of dynamic socio-economic development have caused long-term damage to the river landscapes.

Furthermore, the effects of climate change pose an additional threat to these already endangered ecosystems. The extreme fluctuation between flooding and water scarcity threatens to destroy the habitat along riverscapes and thus the existence of millions of people.

The art project *Riverscapes IN FLUX*, conceptualized and organized by the Goethe-Institut in Vietnam, seeks to create a discourse on this key ecological issue of a new context. The Goethe-Institute invited young artists from Vietnam, Thailand, Cambodia, Myanmar, Indonesia and the Philippines to reflect in their work the ecological as well as socio-economic and cultural changes that the riverscapes in these countries are currently experiencing.

Supported by experienced curators, 17 art works have been created: multimedia installations and photo series, videos and object installations. The exhibition, which celebrated its opening in Hanoi, travels to Ho Chi Min City, Bangkok, Phnom Penh, Jakarta and Manila, accompanied by film screenings and various educational and cultural activities.

With this art project, the Goethe-Institut wants to contribute to raising awareness about the invaluable ecological and cultural heritage of the major river landscapes in Southeast Asia. Accompanying events and especially the exhibition blog offer room for discussion: blog.goethe.de/riverscapes
We hope for a lively exchange between artists and visitors that will flow beyond borders – just like the rivers themselves.

# ទិដ្ឋភាពទន្លេនៅក្នុងការផ្លាស់ប្តូរ ទន្លេនៅអាស៊ីអាគ្នេយ៍ ជាកន្លែងនៃជីវិតនិងជម្លោះ

អាយអូឡា លិនហ្វី

ធម្មជាតិ និងជាតុផ្សំរបស់វាបានចងក្រងជីវិតសង្គម សាសនា និងសិល្បៈរបស់អាស៊ីអាគ្នេយ៍ តាំងពីមុនសម័យទំនើបមកម្លេះ ដោយក្នុងនោះទឹកតែងតែត្រូវបានកត់ត្រាជាផ្នែកមួយយ៉ាងសំខាន់នៅក្នុងប្រវត្តិជំនឿ ទំនៀមទម្លាប់និងសេដ្ឋកិច្ច។ បើទោះជាមានភាពខុសប្លែកគ្នារវាងប្រជាជនក៏ដោយ ក៏តំបន់អាស៊ីអាគ្នេយ៍បានផ្សារភ្ជាប់គ្នាដោយសារទឹក ភាពស្រដៀងគ្នានៃជំនឿនិងទស្សនៈ និងការផ្លាស់ប្តូរគំនិតដែលជាលទ្ធផលនៃពាណិជ្ជកម្មតាមដងទន្លេ និង សមុទ្រ។ ប៉ុន្តែបច្ចុប្បន្ននេះ ចន្លោះប្រហោងនៃភូមិសាស្ត្ររបស់អាស៊ីអាគ្នេយ៍ ក៏ទំនងរំលឹកអំពីផលប៉ះពាល់អវិជ្ជមានមួយ។ សម្រាប់រដ្ឋាភិបាល ទន្លេជាប្រភពនៃកម្លាំងវារីអគ្គីសនី។ ប៉ុន្តែការកសាងទំនប់ទឹកគំរាមកំហែងដល់តុល្យភាពអេកូឡូហ្ស៊ីនៅក្នុងប្រទេសនិងប្រទេសជិតខាង ហើយទន្លេដែលចាំបាច់សម្រាប់វិស័យនេះ អាចជាកន្លែងសម្រាប់ចាក់ចោលនូវសំណល់ឧស្សាហកម្ម។

ក្រុមអភិវឌ្ឍន៍ និងក្រុមអភិរក្សបានអះអាងតំណាលគ្នាថាផ្លូវទឹកសំខាន់ៗដូចជាទន្លេមេគង្គ ដែលមានប្រភពនៅប្រទេសចិនហើយហូរកាត់ប្រទេសមីយ៉ាន់ម៉ា ឡាវ កម្ពុជា ថៃ និងវៀតណាម គឺជាកន្លែងវិវាទកម្ម។ ដូច្នេះនៅក្នុងទឹកដីអាស៊ីអាគ្នេយ៍ ដែលភាគច្រើននៅជាទីជនបទនៅឡើយ ទន្លេមានជិតជាមនូវការពុះពារតស៊ូរវាងទំនើបកម្មនិងប្រពៃណី។ ការប្រែប្រួលទំនាក់ទំនងជាមួយទឹកទន្លេ ក៏បង្កអោយមានភាពតានតឹងជាអន្តរជាតិផងដែរ ខណៈពេលដែលប្រទេសទាំងនោះប្រកែកទាមទារលើការគ្រប់គ្រង និងធនធាន។ បើទោះបីវាជាបញ្ហាសាកលក៏ដោយ ភាពតានតឹងផ្នែកបរិស្ថាននៅអាស៊ីអាគ្នេយ៍មានសភាពធ្ងន់ធ្ងរជាពិសេស ដោយសង្គមស៊ីវិលនៅមានអាយុក្មេងខ្ចី ហើយជាញឹកញាប់បុគ្គលនិងសហគមន៍អាចចូលរួមចំណែកតិចតួចប៉ុណ្ណោះនៅក្នុងការសម្រេចចិត្តរបស់រដ្ឋាភិបាលដែលធ្វើឡើងក្នុងឈ្មោះរបស់ប្រជាជន។ កត្តានេះធ្វើអោយបញ្ហាអេកូឡូហ្ស៊ីគ្រាន់តែជាផ្នែកមួយនៃបញ្ហានយោបាយ និងសង្គមទាំងមូលប៉ុណ្ណោះ។

គម្រោងទិដ្ឋភាពទន្លេនៅក្នុងការផ្លាស់ប្តូរដែលបានផ្តួចផ្តើមដោយ វិទ្យាស្ថាន Goethe-Institut ប្រចាំនៅទីក្រុងហាណូយ ប្រើប្រាស់សិល្បៈចក្ខុទស្សន៍ ដើម្បីពិនិត្យលើទិដ្ឋភាពទំនៀមទន្លាប់និងបញ្ហាប្រឈមអេកូឡូហ្ស៊ីក្នុងសតវត្សទី ២១ របស់ដងទន្លេ។ តាមរយៈទន្លេ ការពិនិត្យតាមដាននេះ ផ្តល់នូវឱកាសដ៏មានអត្ថន័យសម្រាប់ប្រជាជនទាំងអស់នៅក្នុងតំបន់ដើម្បីចាប់ផ្តើមដោះស្រាយតថភាពដ៏ស្មុគស្មាញ និងប្រែប្រួលយ៉ាងឆាប់រហ័សទាំងនេះ (សង្គម នយោបាយ និងវប្បធម៌) ដែលប្រទេសអាស៊ីអាគ្នេយ៍ដីគោកក៏ដូចជាដីកោះកំពុងប្រឈមសព្វថ្ងៃ។ គម្រោងរួមមានស្នាដៃបង្កើតឡើងដោយសិល្បករចំនួន ១៧ រូប និងអ្នករៀបចំកម្មវិធីសិល្បៈនៅក្នុងតំបន់ចំនួន ៦ រូប។ ថ្វីត្បិតតែស្នាដៃទាំងនេះស្ថិតនៅក្នុងកំរិតដែនអាស៊ីក៏ពិតមែន ក៏ភាពពាក់ព័ន្ធនៃប្រធានបទមានលក្ខណៈជាសាកល ហើយសិល្បករដែលចូលរួមពាំនាំនូវកង្វល់ក្នុងប្រទេសរបស់គេដល់ទស្សនិកជនទូទាំងពិភពលោក។ ស្នាដៃទាំងនេះត្រូវបានរៀបចំជាពិសេសសម្រាប់ពិព័រណ៍ចរនៅក្នុងតំបន់។ វាផ្តល់នូវរូបភាពនៃការចូលរួមបច្ចុប្បន្នផ្នែកសង្គមនិងបរិស្ថានរបស់អាស៊ីអាគ្នេយ៍ ក្នុងនាមជាសមាជិកនៃសាធារណៈដែលតស៊ូប្រឈមនឹងវាសនានៃមជ្ឈដ្ឋាននៅជុំវិញ ដោយនៅពេលខ្លះប្រឆាំងនឹងអំណាចនៅក្នុងប្រទេសរបស់គេ។

ក្នុងនាមជាសរសៃឈាមដ៏សំខាន់នៃដែនដីអាស៊ីអាគ្នេយ៍ ទន្លេមេគង្គគឺជាចំនុចភូមិសាស្ត្រ

# Riverscapes IN FLUX
## SOUTHEAST ASIAN RIVERS AS SITES OF LIFE AND STRIFE

Iola Lenzi

Nature and its elements have structured Southeast Asian social religious and artistic life from pre-modern times; water holds a supreme place in mythology, ritual and economic history. Despite the diversity of its people, Southeast Asia has been cemented by the waters, regional syncreticism and fostered by the exchanges of ideas resulting from riverine and sea trade.  But today, Southeast Asia's geographic porousness may also harbour a negative impact. For governments, rivers are sources of hydroelectric capacity. Dam building however threatens ecological balance locally and across national boundaries, and rivers, indispensable to industry, are dumping-grounds for industrial garbage.

Major waterways such as the Mekong, born in China, crossing Myanmar, Laos, Cambodia, Thailand and Vietnam, are therefore sites of contestation, simultaneously claimed by partisans of development and conservation. Thus, in still predominantly rural Southeast Asia, the river embodies struggle between modernity and tradition. Changing relationships to water also feed international tension as the different countries sharing it spar over control and resources. Global as it is, environmental stress is particularly acute in Southeast Asia where civil society is nascent and individuals and communities often have little say in government decisions made in their name; ecological issues are part of greater political and social ones.

*Riverscapes IN FLUX*, initiated by Goethe-Institut Hanoi, investigates through visual art the river's scapes, traditions and 21st century ecological challenges. This examination offers the opportunity, via the river, meaningful to all regional citizens, to tackle the complex and fast evolving realities – social, political, cultural – facing mainland and insular Southeast Asia today. The project includes works by 17 regional artists, selected by six regional curators. Though Asian in scope, its relevance is global; the participants bring local concerns to a universal audience. Specially commissioned for regional tour, the pieces, many cross-disciplinary, provide a snapshot of current Southeast Asian social and environmental engagement as members of the public are emboldened to challenge the fate of their surroundings, sometimes at odds with the powers running their nation.

As a vital artery of mainland Southeast Asia, the great Mekong River figures as a geographic starting point for FLUX. However, insular artists from Indonesia and Philippines, and Mekong-country artists too, put other environmentally tainted waterways at the heart of their work.

FLUX practitioners adopt different expressive approaches and genres to prod a central topic, environmental change and degradation. Many bring community into their strategy, either initiating community involvement at the time of creation, or else requesting it of gallery-goers at the exhibition-site. Some pieces are performative, evolving over space and time, production processes documented for viewers.

Several, mapping life on the river, transcend the literal aspect of representation. Elucidating the confrontation between traditional and development economics responsible for damage and change, they allude to moral and cultural consequences. But these are probed questioningly, the work exposing discomfort rather than adopting a one-sided critical tack. Saigon performance and multi-media artist **Phan Thao Nguyen**, with her *Mekong Mechanical* documents change without judging, conveying a shifting grey-zone complexity that underpins both environmental and social change in contemporary Southeast Asia.

Others are cryptic: Cambodian **Lim Sokchanlina**'s ice piece *Rising Tonle Sap*

ចាប់ផ្តើមដ៏ច្បាស់មួយសម្រាប់គម្រោងទិដ្ឋភាពទន្លេនៅក្នុងការផ្លាស់ប្តូរនេះ។ ប៉ុន្តែទោះជាដូច្នេះក្តី ទាំងសិល្បករពីដែនកោះដូចជាប្រទេសឥណ្ឌូនេស៊ីនិងហ្វីលីពីន និងសិល្បករមកពីប្រទេសមេគង្គ ក៏បានដាក់បញ្ចូលផ្លូវទឹកដទៃទៀតដែលទទួលរងផលប៉ះពាល់បរិស្ថានផងដែរចូលនៅក្នុងបេះដូងនៃស្នាដៃរបស់ពួកគេ។

សិល្បករនៃគម្រោងទិដ្ឋភាពទន្លេនៅក្នុងការផ្លាស់ប្តូរ ប្រើប្រាស់វិធីសាស្ត្រនិងប្រភេទផ្សេងៗគ្នានៅក្នុងការបង្ហាញ ដើម្បីពិភាក្សាលើប្រធានបទកណ្តាលមួយគឺ ឱនភាពនិងភាពប្រែប្រួលនៃបរិស្ថាន។ មានសិល្បករជាច្រើនលើកយកសហគមន៍មកបញ្ចូលនៅក្នុងយុទ្ធសាស្ត្ររបស់គេ មិនថាផ្តួចផ្តើមអោយមានការចូលរួមពីសហគមន៍នៅក្នុងពេលបង្កើតស្នាដៃ រឺក៏អញ្ជើញការចូលរួមពីសំណាក់អ្នកទស្សនានៅក្នុងសាលពិព័រណ៍នោះទេ។ ស្នាដៃខ្លះមានលក្ខណៈសំដែងនៅក្នុងអំឡុងពេលនិងនៅទីកន្លែងណាមួយ និងមានកំណត់ត្រាឯកសារសម្រាប់អោយអ្នកទស្សនាបានស្វែងយល់ផងដែរ។

ស្នាដៃខ្លះទៀតបង្ហាញពីជីវិតនៅលើទន្លេនិងឆ្លុះបញ្ចាំងលើសពីភាពជាតំណាងដោយចំៗទៅទៀត។ ដោយលើកឡើងពីភាពប្រឈមមុខគ្នារវាងសេដ្ឋកិច្ចបុរាណនិងសេដ្ឋកិច្ចអភិវឌ្ឍន៍ដែលទទួលខុសត្រូវចំពោះភាពខូចខាតនិងប្រែប្រួលបរិស្ថាន ស្នាដៃទាំងនេះហាក់ចង្អុលអោយឃើញនូវផលវិបាកផ្នែកវប្បធម៌និងសីលធម៌មួយចំនួន។ ប៉ុន្តែបញ្ហាទាំងនេះត្រូវបានពិនិត្យនិងចោទសួរ ពេលខ្លះបង្ហាញនូវភាពមិនសុខស្រួលជាជាងប្រើប្រាស់ការវិភាគលំអៀងតែម្ខាង។ សិល្បករសម្តែងនិងមីឌាចំរុះ( multi-media ) ប្រចាំទីក្រុងសាយហ្គន **ផាន់ថៅ ង្វុយិន** ប្រើប្រាស់ស្នាដៃ "មេកានិកមេគង្គ" ដើម្បីកត់ត្រាដោយមិនកាត់ក្តី ពីភាពស្មុគស្មាញនៃតំបន់សដែលកំពុងប្រែប្រួល និងសង្កត់ធ្ងន់លើការផ្លាស់ប្តូរទាំងផ្នែកបរិស្ថាននិងសង្គម នៅក្នុងអាស៊ីអាគ្នេយ៍បច្ចុប្បន្ន។

ស្នាដៃខ្លះទៀតមានលក្ខណៈអាថ៌កំបាំងដូចជារូបថតទឹកកករបស់សិល្បករខ្មែរ **លឹម សុខចាន់លីណា** ដែលមានចំណងជើងថា "ទឹកឡើងនៅទន្លេសាប" បង្ហាញពីកំណត់ត្រារូបភាពនៃការសម្តែងជាមួយទឹកកកអណ្តែតតាមដងទន្លេសាប ដែលមានលក្ខណៈជំនឿនិងលន្លង់លន្លោច។ សកម្មភាពប្រណីតនេះពោរពេញទៅដោយសោភ័ណភាពប៉ុន្តែធ្វើអោយរំខានចិត្តព្រោះណែនាំពីការផ្លាស់ប្តូរនិងការបាត់បង់ទាក់ទងនឹងផលប៉ះពាល់ផ្នែកអេកូឡូហ្សី និងការប្រែប្រួលអាកាសធាតុ ក៏ដូចជាវដ្តនៃជីវិត។

ដោយផ្សារភ្ជាប់ការបាត់បង់ និងភាពចម្លែក សិល្បករខ្មែរ **ថន សុខ** បង្កើតស្នាដៃតម្លើងទីងមោង និងវីដេអូឈ្មោះថា "ទំនាបកណ្តាល"។ ស្នាដៃនេះ បង្ហាញយ៉ាងស្តែងអំពីទស្សនៈនៃភាពមិនទៀងទាត់ និងភាពទទេ ដែលគេស្គាល់យ៉ាងទូលំទូលាយនៅក្នុងតំបន់នេះ និងអំពីទិដ្ឋភាពចក្ខុទស្សន៍ដែលមានន័យសម្រាប់ជាតិសាសន៍អាស៊ីអាគ្នេយ៍ទាំងអស់។ វាផ្ទុយនឹងវដ្តដែលអាចប៉ាន់ស្មានបាន និងការរំខាននៃភាពប្រែប្រួលបរិស្ថានដែលបង្កដោយមនុស្ស។

សិល្បករថៃ **ស៊ូធីរ៉ាត់ ស៊ូប៉ាប៉ារិនយ៉ា** ជាមួយនឹងស្នាដៃតម្លើងវីដេអូឈ្មោះថា "ផ្លូវរបស់ជីតាខ្ញុំត្រូវបានឃាំងជារៀងរហូត" ប្រើប្រាស់ប្រវត្តិគ្រួសារនិងការអាឡោះអាល័យ ដើម្បីប្រឈមដោយប្រយោលនឹងអតីតកាល និងបច្ចុប្បន្នកាលនៃទន្លេ។

ចំពោះស្នាដៃដែលប្រើប្រាស់សំលេងជាចំបង បង្ហាញពីការបន្តប្រើប្រាស់បច្ចេកទេសចំរុះរបស់សិល្បករនៅក្នុងតំបន់ និងការយល់ដឹងរបស់គេអំពីឥទ្ធិពលនៃសំលេង តាមរយៈការបញ្ចូលអត្ថន័យជីវិតសហគមន៍។ អ្នកនិពន្ធភ្លេងនិងតន្ត្រីករមកពីទីក្រុងហាណូយ **លួងហ៊ូ ទ្វីង** បង្កើតស្នាដៃសាកល្បងឈ្មោះ "រង្វង់ខ្មៅ" ដែលបានពីការបញ្ចូលគ្នានូវទិន្នន័យគ្រោះធម្មជាតិ និងខ្សែអាត់សំលេងនិងសម្តីជាច្រើន ក្នុងនោះរួមមានសំលេងភ្លេងភូមិភាគខាងត្បូង តៃទូ ដែលមានដើមកំណើតពីតន្ត្រីរាជវាំងនៅតំបន់ហ៊្វេ។ ស្នាដៃ

បញ្ចូលគ្នារវាងរូបនិងសំលេងរបស់គាត់ សំដៅលើការប្រៀបធៀបដ៏ប៉ិនប្រសប់ដល់កម្លាំងនិងចំណាប់អារម្មណ៍តតាំងនៅក្នុងប្រទេសវៀតណាមបច្ចុប្បន្ន។ ស្នាដៃ “ទ្បើងនិងស្រក រះនិងលិច” របស់សិល្បករខ្មែរ **វុធ លីណូ** បញ្ជាក់ពីសំលេងទឹកទន្លេ ចេញពីផ្ទះគំរូតូចមួយសង់លើសសរផុតដី ដែលក៏តំណាងអោយខ្ទមអ្នកតាផងដែរ។

តាមរយៈសិល្បៈ និងទន្លេជានិមិត្តសញ្ញា គម្រោងទិដ្ឋភាពទន្លេនៅក្នុងការផ្លាស់ប្តូរ ពិនិត្យលើបញ្ហាមួយនៃបញ្ហាតានតឹងជាច្រើនដែលនឹងកំនត់អនាគតរបស់ប្រជាជនជំនាន់នេះ គឺការស្វែងរកតុល្យភាពរវាងតម្រូវការសេដ្ឋកិច្ច និងការអភិរក្សបរិស្ថាន។ ទាំងភាពមិនអើពើ ដែលកើតចេញពីការផ្លាស់ប្តូរសង្គម រឺក៏អសមត្ថភាពនៃការគ្រប់គ្រងជោគវាសនារបស់ទន្លេ មិនថាផ្នែកណាមួយត្រូវទទួលខុសត្រូវនោះទេ វាច្បាស់ណាស់ថាទន្លេដែលជាគូរកននិងប្រភពនៃជីវិត ឥទ្បូវនេះក៏គឺជាកន្លែងនៃជម្លោះផងដែរ។ ស្នាដៃនៅក្នុងគម្រោងនេះ ដែលចោទសួរជាជាងថ្លែងប្រាប់ និងពេលខ្លះមានលក្ខណៈលន្លង់លន្លោច បើទោះជាបញ្ហាមិនគួរអោយរីករាយក៏ដោយ បានពង្រីកព្រំដែនប្រធានបទអេកូទ្បូហ្សីនៃគម្រោងនេះ ដើម្បីផ្តល់នូវទស្សនៈឆ្លើយឆ្លងគ្នាជាច្រើន អំពីភាពស្មុគស្មាញនៃអាស៊ីអាគ្នេយ៍បច្ចុប្បន្ន។

comprises photographs documenting a poetic, ritualistic performance of melting ice blocs floated down the Tonle Sap river. Aesthetic but also subtly disturbing, the elegant action suggests the change and loss associated with ecological disturbance and climate change, as well, more universally, as the life cycle.

Tinged with irony as well as loss, is Cambodian **Than Sok**'s *Middle Ground*, a video installation with scarecrows, superimposes regionally-familiar concepts of temporality and nothingness using rural visual cues meaningful to all Southeast Asians.

Thai artist **Sutthirat Supaparinya**, with her meditative *My Grandpa's Route Has Been Forever Blocked* video installation, uses nostalgia and family history to allusively confront the river's past and present.

Pieces dominated by sound testify to regional artists' ongoing cross-disciplinary tack, and their understanding of sound's appeal through its connotation of community life. Hanoi composure/musician **Luong Hue Trinh** creates her experimental *Black Circle* meshing clinically-listed natural disaster data, and lyrical tapestry of sound and voice including elements of the court music of Hue. Luong's audiovisual collage constitutes a subtle metaphor for opposing interests and forces in contemporary Vietnam. Cambodian **Vuth Lyno**'s *Rise and Fall* presents a composition of river noises emerging from a miniature house on stilts that also resembles a traditional Cambodian spirit house.

Through art and the river-as-symbol, *Riverscapes IN FLUX* tackles one of the most future-defining stresses of this generation: the quest for balance between economic needs and environmental conservation. Whichever is responsible, a disregard born of social change, or an inability to control the river's fate, there is no doubting that the river, once an ally and source of livelihood, is now a site of strife. The FLUX works, questioning rather than stating, enlarge the project's ecological framework to offer intersecting perspectives on the complexities of Southeast Asia today.

# កម្ពុជា

## អេរិន ឃ្លីសិន

ពេលខ្ញុំត្រូវបានអញ្ជើញឲ្យចូលរួមក្នុងគម្រោងទិដ្ឋភាពទន្លេនៅក្នុងការផ្លាស់ប្តូរ ពេលនោះទឹកជំនន់ឆ្នាំ ២០១១ នៅក្នុងប្រទេសកម្ពុជាកំពុងឡើងខ្ពស់បំផុត។ ខ្ញុំតែងមានទំនោរប្រយ័ត្នប្រយែង និងរិះគន់ចំពោះពិធីពិព័រណ៍ទាំងឡាយណា ដែលសិល្បករត្រូវបានអញ្ជើញឲ្យបម្រើដល់ប្រធានបទទូលំទូលាយដូចជាការប្រែប្រួលអាកាសធាតុជាដើម (ដែលគ្មានសិល្បករថ្មោងថ្មីណាម្នាក់នៅក្នុងប្រទេសកម្ពុជាលើកឡើងជាពិសេសនោះទេ)។ ប៉ុន្តែ គឺដោយសារតេថភាពគួរឲ្យខ្លាចរបស់ទឹកជំនន់ និងភាពជាក់លាក់នៃគម្រោងនេះចំពោះទន្លេ ដែលបានធ្វើឲ្យខ្ញុំពិចារណាឡើងវិញអំពីតួនាទីដ៏មានអត្ថន័យនៃពិធីពិព័រណ៍បែបនេះដែលអាចមានសម្រាប់សិល្បករនិងទស្សនិកជន។ សិល្បករហាក់ដូចជានៅមានមន្ទិលដូចៗគ្នា។ ពួកគេមិនដែលបានធ្វើការទាក់ទងជាមួយទន្លេពីមុនឡើយ ប៉ុន្តែការចង់ដឹងចង់យល់បានទាក់អារម្មណ៍ពួកគេ ដោយសារពួកគេបានចាប់ផ្តើមចំណាយពេលវេលានៅក្នុងទីតាំងខុសៗគ្នានៅលើខ្សែទឹកតែមួយ គឺទន្លេសាប ដែលជាបឹងនិងទន្លេមួយដែលហូរចូលប្រទេសកម្ពុជា ហើយជាទន្លេតែមួយនៅក្នុងពិភពលោកដែលផ្លាស់ប្តូរទិសដៅលំហូរជារៀងរាល់ឆ្នាំនៅក្នុងរដូវវស្សា ដោយសារទន្លេមេគង្គ។

លទ្ធផលស្នាដៃ បានពង្រីកការអនុវត្តន៍ស្នាដៃរបស់សិល្បករប្រកបដោយអត្ថន័យ និងបង្កើតរូបភាពជាពិសេសដោយឡែកនៃអេកូឡូហ្ស៊ីបែបវប្បធម៌ និងបរិស្ថានរបស់បឹងទន្លេសាប។ សិល្បករ **វុធ លីណូ** ដែលថ្មីៗនេះបានរៀបចំពិព័រណ៍សិល្បៈសំលេងបែបសហគមន៍មួយបានដកពិសោធន៍ជាមួយសំលេងក្នុងអំឡុងពេលស្នាក់នៅរបស់គាត់ជាមួយសហគមន៍ទន្លេនិងព្រៃលិចទឹកនៅ កំពង់ភ្លុក។ សិល្បករ **ថន សុខ** ប្រើសម្ភារៈប្រចាំថ្ងៃដើម្បីចោទសួរនូវទម្លាប់ផ្នែកជំនឿ។ គាត់បានប្រើរូបទីងមោងជាតំណាងដើម្បីចែករំលែកបទពិសោធន៍ផ្ទាល់ខ្លួនរបស់គ្រួសារគាត់ដែលរស់នៅជិតទន្លេសាប និងត្រូវបានជន់លិចនៅភ្នំពេញ។ គម្រោងថតរូបរបស់សិល្បករ **លីម សុខចាន់លីណា** បានបង្ហាញពីទំនាក់ទំនងរវាងកម្រិតទឹកនិងអាកាសធាតុដែលកើនឡើង តាមរយៈការបង្កើតទិដ្ឋភាពដ៏អស្ចារ្យនៃដុំទឹកកកឧស្សាហកម្មកំពុងរលាយ ជាមួយនឹងរូបបឹងទន្លេសាបនៅផ្ទៃខាងក្រោយ។ សិល្បករនិងខ្ញុំ រំពឹងថានឹងធ្វើការសន្ទនាលើស្នាដៃទាំងនេះជាមួយទស្សនវិស័យក្នុងតំបន់ជាច្រើនផ្សេងទៀតនៅក្នុងគម្រោងនេះ។

អេរិន ឃ្លីសិន កើតនៅក្រុង Minneapolis នៅឆ្នាំ ១៩៧៩។ គាត់គឺជានាយកផ្នែកសិល្បៈនិងសហស្ថាបនិករបស់វិចិត្រសាលនិងមណ្ឌលធនធានមួយឈ្មោះស-សបាសាក់ នៅទីក្រុងភ្នំពេញ ដែលនៅក្នុងឆ្នាំ ២០១១ (ជាឆ្នាំទីមួយរបស់ខ្លួន) បានផ្តោតលើការរៀបចំកម្មវិធីពិព័រណ៍សិល្បៈទោល សម្រាប់បណ្តាសិល្បករនាំមុខនៅកម្ពុជា និងកំពុងពង្រីកកម្មវិធីសាធារណៈជាច្រើនទៅដល់ទស្សនិកជនក្នុងស្រុក។

ដោយប្រចាំការនៅក្នុងប្រទេសកម្ពុជាចាប់តាំងពីឆ្នាំ ២០០១ មក ឃ្លីសិនបានរៀបចំកម្មវិធីពិព័រណ៍សិល្បៈទោលនិងជាក្រុមជាច្រើន ហើយបានចែករំលែកការបង្រៀនអំពីទិដ្ឋភាពផ្សេងៗនៃសិល្បៈសហសម័យពីប្រទេសកម្ពុជា ជាមួយដៃគូជាច្រើនដូចជា វិទ្យាស្ថានសិល្បៈសហសម័យសិង្ហបុរី មណ្ឌល Artsonje កម្មវិធីពិព័រណ៍អាស៊ីប៉ាស៊ីហ្វិករយៈពេលបីឆ្នាំម្តង(APT) ប័ណ្ណសារសិល្បៈអាស៊ី សាលសិល្បៈPara/Site វិទ្យាស្ថាន The Sotheby's Institute និងមជ្ឈមណ្ឌលសម្រាប់ការសិក្សារៀបចំកម្មវិធីសិល្បៈនៅមហាវិទ្យាល័យ Bard។ គម្រោងខាងមុខរបស់គាត់រួមមាន ការតាំងពិព័រណ៍ជាក្រុម និងការបោះពុម្ពផ្សាយ "ភ្នំពេញ៖សង្គ្រោះបុរាណវិទ្យា" នៅ IFA ក្រុងប៊ែរឡាំង និងក្រុងស្ទុតហ្គាត (២០១៣) ហើយគាត់ជាសហអ្នករៀបចំពិព័រណ៍ជាមួយ Leeza Ahmady នៅក្នុងកម្មវិធី Season of Cambodia ដែលជាមហោស្រពសិល្បៈខ្មែរនៅក្រុងញូយ៉ក។

# CAMBODIA

## Erin Gleeson

When I was invited to take part in *RiverScapes IN FLUX* project, the 2011 floodwaters in Cambodia were at their height. Whereas I tend to be critical of exhibitions for which artists are invited to service broad themes such as climate change – which no emerging artist in Cambodia was specifically addressing - it was the terrible reality of the floods and the specificity of the project to the river that made me reconsider the meaningful role such exhibitions can have for artists and audiences alike. The artists seemed equally skeptical; they had never considered the river as source material, yet their curiosity piqued as they began spending time in different locations on the same water vein – the Tonle Sap - a lake and river isolated to Cambodia and unique as the only river in the world to reverse directions annually, forced by the Mekong River in monsoon.

The resulting works meaningfully extend the artist's practices, while creating a unique portrait of the Tonle Sap's environmental and cultural ecology. Vuth Lyno, who had recently curated a community sound project, was able to experiment with sound drawn from his residency with a river-based community in the flooded forest of Kompong Pluk. Than Sok, who uses everyday materials to question spiritual practices, used the metaphor of the scarecrow to share his family's personal experience living near and being flooded by the Tonle Sap in Phnom Penh. Lim Sokchanlina's photography project considered the relationship between rising temperatures and water levels by staging fantastical scenes with industrial ice blocks melting against diverse backdrops of the Tonle Sap. The artists and I look forward to placing these works in conversation with the many other regional perspectives in this project.

Erin Gleeson, born in Minneapolis in 1979, is the Artistic Director and co-founder of SA SA BASSAC, a gallery and resource center in Phnom Penh which, in its first year, 2011, focused on curating foundational solo exhibitions for Cambodia's leading artists while extending numerous public programs to local audiences.

Based in Cambodia since 2001, Gleeson has curated many solo and group exhibitions, and has shared lectures on various aspects of contemporary art from Cambodia with such partners as Institute of Contemporary Arts Singapore, Artsonje Center, Asia Pacific Triennial, Asia Art Archive, Para/Site Art Space, The Sotheby's Institute, and Center for Curatorial Studies, Bard College. Her forthcoming projects include the group exhibition and publication *Phnom Penh: Rescue Archeology*, IFA, Berlin and Stuttgart (2013) and her work as visual arts co-curator with Leeza Ahmady for *Season of Cambodia*, a citywide festival of Cambodian art in New York City.

# វៀតណាម
# ទន្លេយំ

## ចាន់ លួង

អស់រយៈពេលរាប់ពាន់ឆ្នាំមកហើយ ទន្លេផ្តល់ភោគផលចំពោះការអភិវឌ្ឍន៍របស់មនុស្សជាតិ។ សម្រស់ដ៏ដក់ជាប់បេះដូងរបស់ទេសភាពទន្លេ បានបណ្តុះនូវអារម្មណ៍និងព្រលឹងរបស់មនុស្សជាតិ។

ទិដ្ឋភាពទន្លេនៅក្នុងការផ្លាស់ប្តូរ គឺជាគម្រោងសិល្បៈស្មុគស្មាញមួយ និងជាការភ្ជាប់ទំនាក់ទំនងរវាងគម្រោងសិល្បៈបែបទ្រឹស្តី និងគម្រោងអភិវឌ្ឍន៍សង្គម។

វាសនារសាត់របស់ "Đờn ca tài tử" បានចាប់ផ្តើមនៅក្នុងរាជធានីបុរាណហ៊ូ កាលពី ៤០០ ឆ្នាំមុន ហើយបានចាក់ឫសនិងវិវត្តតាមពេលវេលាក្លាយជាវិញ្ញាណវប្បធម៌មួយដ៏ពិសេសចំពោះដែនដីសណ្តរមេគង្គ។ ប៉ុន្តែឥឡូវនេះ វាកំពុងទទួលរងឥទ្ធិពលយ៉ាងធ្ងន់ធ្ងរពីការប្រែប្រួលបរិស្ថានរស់នៅបែបបុរាណ និងការផ្លាស់ប្តូរទម្រង់ទំនាក់ទំនងរវាងមនុស្សជាតិនិងទន្លេ។ ស្នាដៃសិល្បៈសម្តែង "រង្វង់ខ្មៅ" ដែលឆ្នៃប្រឌិតដោយ លួងហ៊ូ ទ្រីញ គឺបង្ហាញអំពីរឿងរ៉ាវស្នេហាមិនប្រាកដមួយ ដែលកើតឡើងនៅក្នុងកាលៈទេសៈអភ័ព្វនេះ។

សាច់ត្រីអណ្តែង ដែលតំរៀបជាបន្តបន្ទាប់គ្នានៅលើម៉ាស៊ីនសម្ងួត បង្កើតបានជារូបភាពមួយដែលប្លែកនិងទាក់អារម្មណ៍។ តាមរយៈទស្សនីយភាពដោយផ្ទាល់នៃដែនដីសណ្តរមេគង្គ ស្នាដៃសិល្បៈរបស់ ផាន់ថៅ ង្វៀន បង្ហាញពីការប្រឆាំងគ្នាដ៏ជ្រាលជ្រៅមួយរវាងបរិស្ថានធម្មជាតិ និងវប្បធម៌ ជាមួយកម្មវត្ថុអភិវឌ្ឍន៍សេដ្ឋកិច្ច និងឆ្លុះបញ្ចាំងពីភាពត្រដាក់ខុសធម្មតានៃជីវិតដែលត្រូវបានធ្វើឧស្សាហូបនីយកម្ម នៅក្នុងរោងចក្រកែច្នៃត្រីអណ្តែង។

ក្រៅពីការផ្សំសិល្បៈជាមួយបទពិសោធន៍ជីវិតពិត អ្វីដែលគួរឲ្យកត់សម្គាល់អំពីសិល្បៈសហសម័យ ក្នុងបែបជាទំនោរទូទៅមួយ និងស្តីអំពីស្នាដៃសិល្បៈនៅក្នុងគម្រោងនេះ គឺជាអាកប្បកិរិយារបស់សិល្បករក្នុងនាមជាពលរដ្ឋដែលមានការទទួលខុសត្រូវ!

ចាន់ លួង កើតក្នុងឆ្នាំ ១៩៦០។ គាត់គឺជាសិល្បកររចក្ខុទស្សន៍ និងជាអ្នករៀបចំពិព័រណ៍មួយរូបមកពីប្រទេសវៀតណាម។ គាត់បានបញ្ចប់ការសិក្សានៅមហាវិទ្យាល័យវិចិត្រសិល្បៈហាណូយ នៅឆ្នាំ ១៩៨៣ ដែលជាឆ្នាំគាត់បានបង្កើតក្រុមសិល្បករ Gang of Five។ ស្នាដៃអរូបិយរបស់គាត់ ត្រូវបានបង្ហាញនៅក្នុងកម្មវិធីពិព័រណ៍ជាក្រុមនៅវិទ្យាស្ថាន Goethe ក្រុងហាណូយ ប្រទេសវៀតណាម, សារៈមន្ទីរត្រូពិក នៅក្រុងអាំស្ទែរដាម ប្រទេសហូឡង់, ពិព័រណ៍ Liverpool Biennial of Contemporary Art ឆ្នាំ ២០០២ នៅប្រទេសអង់គ្លេស, និងកម្មវិធីពិព័រណ៍ Fukuoka Asian Biennale នៅប្រទេសជប៉ុន។ ប្រហែលដប់ឆ្នាំកន្លងមកនេះ លួង បាននិងកំពុងផ្តោតលើសិល្បៈតម្លើងនិងសិល្បៈសម្តែងដែលមានលក្ខណៈដូចគំនូររបស់គាត់ដែរ ដែលគូរពីបទពិសោធន៍និងបញ្ហានៅក្នុងជីវិតរបស់ខ្លួនគាត់ផ្ទាល់ ឧទាហរណ៍ ដូចជាការបាត់បង់តម្លៃប្រពៃណីដែលជំនាន់របស់គាត់កំពុងប្រឈមមុខ។ នៅក្នុងឆ្នាំ ២០០០ លួង បានបង្កើតមជ្ឈមណ្ឌលសិល្បៈសហសម័យនៅក្នុងទីក្រុងហាណូយ ដែលគាត់បានតំណាងក្នុងឋានៈជានាយកសិល្បៈរហូតដល់ចុងឆ្នាំ ២០០៣។ គាត់ត្រូវបានចាត់ទុកថាជាអន្តរការីសំខាន់បំផុតនៃសិល្បៈសហសម័យនៅក្នុងប្រទេសវៀតណាម។ គាត់បានរៀបចំសិក្ខាសាលាផ្សេងៗជាច្រើនសម្រាប់សិល្បករក្មេងៗ និងបានរៀបចំមហោស្រពសម្តែង និងកម្មវិធីតាំងពិព័រណ៍ ដែលក្នុងចំណោមនោះ កម្មវិធីខ្លះត្រូវបានរៀបចំក្នុងកិច្ចសហប្រតិបត្តិការជាមួយវិទ្យាស្ថាន Goethe-Institute ហាណូយ។

# VIETNAM
## WEEPING RIVERS

## Tran Luong

For thousands of years now, rivers have been integral to mankind's development. The heart-melting beauty of riverscape has nurtured mankind's feelings and souls.

*Riverscape IN FLUX* is a complex arts project, a marriage between an academic arts project and a social development project.

The floating fate of "Đờn ca tài tử" started in the ancient capital of Hue more than 400 years ago, taking root and over time becoming a cultural spirit iconic to the Mekong river delta. However, it is now being heavily affected by changes to the traditional living environment and the deformation of the relationship between mankind and rivers. The sound artwork Vòng tròn đen (*Black Circle*) by Luong Hue Trinh is about an uncertain love story happening under such eventful circumstances.

Schools of catfish fillet, swim one after another into a flow on a drying machine, creating an impressive exotic image. From another, more direct view of the Mekong Delta, the artwork by Phan Thi Thao Nguyen presents a deep conflict between natural and cultural environment and economic development objectives, reflecting the unusual coldness of industrialized life in a catfish processing factory.

Apart from combining arts with real life experiences, what stands out about contemporary arts as a trend in general and about the artworks in this project in particular is the attitude of artists as responsible citizens!

Tran Luong, born in 1960, is a visual artist and curator from Vietnam. He finished his studies at the Hanoi College of Fine Arts in 1983; in the same year, he founded the artist collective Gang of Five. His progressively abstract works have been showcased in group exhibitions in at the Goethe-Institut Hanoi, Vietnam; the Museum of the Tropics in Amsterdam, the Netherlands; the *Liverpool Biennial of Contemporary Art* 2002, England; and the *Fukuoka Asian Biennal*, Japan. For about ten years, Luong has also been concentrating on installations and performative art, which much like his paintings draw from experiences and problems in his own life, for example the loss of traditional values which his generation is confronted with. In 2000, Luong founded the Contemporary Art Centre in Hanoi, which he represented as art director until the end of 2003. He is considered to be the most important mediator of contemporary art in Vietnam; he has organized various workshops for young artists and has curated performance festivals and exhibitions, among others in collaboration with the Goethe-Institut Hanoi.

# ថៃ

## អាពីសាក់ សុនយ៉ូដ

នៅក្នុងអំឡុងពេលឆ្ពោះទៅកាន់គម្រោង ទិដ្ឋភាពទន្លេនៅក្នុងការផ្លាស់ប្ដូរ បាងកកដែលជារាជធានីរបស់ប្រទេសថៃ បានរងប៉ះពាល់យ៉ាងធ្ងន់ធ្ងរពីទឹកជំនន់។ ប្រជាជនរបស់យើង ត្រូវបានបំបាក់ដោយភាពតក់ស្លុត ហើយសន្ទប់ចិត្តដោយការខូចខាតដែលកើតឡើងក្នុងកំឡុងពេលនិងបន្ទាប់ពីទឹកជំនន់។ ទិដ្ឋភាពទន្លេនៅក្នុងការផ្លាស់ប្ដូរ បង្ហាញពីទស្សនវិស័យរបស់សិល្បករថៃបីរូបចំពោះតំបន់នានានៅតំបន់ភាគខាងជើង ភាគឦសាន និងភាគកណ្ដាល ព្រមទាំងទីក្រុងបាងកកផងដែរ ដែលឥឡូវនេះទើបតែបានធូរស្រាលពីទឹកជំនន់។

អ្នកនាង ស៊ូធីរ៉ាត់ ស៊ូប៉ាប៉ារិនយ៉ា ផ្ដោតលើតំបន់ភាគខាងជើងរបស់ប្រទេសថៃ ដែលមានប្រភពក្បាលទឹកភាគច្រើនបំផុត ប៉ុន្តែក៏ជាតំបន់ដែលប្រឈមមុខនឹងការប្រែប្រួលផ្នែកបរិស្ថានតាមរយៈការសាងសង់ទំនប់ទឹកផងដែរ។

ខណៈពេលដែលទឹកជំនន់អាចនឹងត្រឡប់មកម្ដងទៀត ហើយសូម្បីតែនៅពេលឥឡូវផ្ទះខ្លះក៏មិនទាន់ទាំងស្ងួតនិងសម្អាតបានស្អាតស្រួលបួលផងនោះ ស្នាដៃសិល្បៈដែលឆ្នៃប្រឌិតដោយសិល្បករថៃទាំងបីរូបនេះនៅតែពាក់ព័ន្ធជាងពេលណាណាទាំងអស់។

អាពីសាក់ សុនយ៉ូដ កើតនៅឆ្នាំ ១៩៧២។ គាត់គឺជានាយកនៃ វិទ្យាស្ថានសិល្បៈសហសម័យ Tandu នៅទីក្រុងបាងកក ប្រទេសថៃ។ គាត់បានទទួលបរិញ្ញាប័ត្រផ្នែកទីផ្សារ ហើយក្រោយមកបានបញ្ចប់ការសិក្សាថ្នាក់អនុបណ្ឌិតផ្នែកគ្រប់គ្រងវប្បធម៌ នៅសាកលវិទ្យាល័យ Thammasat ប្រទេសថៃ ក្នុងឆ្នាំ ២០០៣។ ក្នុងនាមជាអ្នករៀបចំពិព័រណ៍មួយរូប អាពីសាក់ សុនយ៉ូដ បានចូលរួមក្នុងគម្រោងជាច្រើនទាំងកម្មវិធីពិព័រណ៍ក្នុងប្រទេសនិងអន្តរជាតិ។ គាត់ធ្លាប់ជាសហនាយកនៃកម្មវិធីពិព័រណ៍ "ខណៈពេលផ្អាក (The Suspended Moment)" ដែលរៀបចំដោយ H&F Collection ក្នុងឆ្នាំ២០០៦ ហើយធ្លាប់ត្រូវបានជ្រើសរើសធ្វើជាអ្នករៀបចំពិព័រណ៍សិល្បៈថៃដើម្បីបង្ហាញពន្លាថៃ (Thai Pavilion) នៅក្នុងពិព័រណ៍សិល្បៈ Venice Biennale លើកទី ៥២ នៅឆ្នាំ ២០០៧។ ពីឆ្នាំ ២០០៨ ដល់ ២០០៩ គាត់បានសហការរៀបចំនូវកម្មវិធីពិព័រណ៍ជាក្រុម "ក្រុងថេប ២២៦ (The Krungthep 226): កម្មវិធីពិព័រណ៍សិល្បៈអំពីទីក្រុងបាងកក ចាប់ពីសម័យកាលដំបូងរហូតដល់សម័យកាលអនាគតក្នុងក្ដីស្រមៃ" នៅឯមណ្ឌលសិល្បៈនិងវប្បធម៌បាងកក។ គាត់ធ្វើការក្នុងវិស័យសិល្បៈនិងវប្បធម៌សហសម័យតាមបែបផ្សេងៗជាច្រើន។ បច្ចុប្បន្ននេះ គាត់គឺជានាយកនៃគម្រោងសហគមន៍មួយ ដែលមានឈ្មោះថា "ការដើរលំហែតាមច្រកនានា រំឭកពីរឿងព្រេងរបស់ Promprab និង Phanakorn, បាងកក"។

# THAILAND

## Apisak Sonjod

In the time leading up to *Riverscapes IN FLUX*, Bangkok, the capital of Thailand, was severely affected by floods. Our people were overcome by shock and overwhelmed with the damage that occurred during and after these floods. Riverscapes INFLUX presents the perspectives of three Thai artists on areas in the North, the North-East, the Central Region as well as Bangkok, which are just now recovering from the floods.

Ms. Sutthirat Supaparinya focuses on the northern region of Thailand, the origin of most riverheads but also an area that faces ecological change through the construction of dams.

With there being a chance of the floods returning when even now some houses are not quite dry and have not even been cleaned up yet, the artworks created by these three Thai artists remain more relevant than ever.

Apisak Sonjod, born in 1972, is the director of Tandu Contemporary Art in Bangkok, Thailand. He obtained a Bachelor's degree in Marketing and later completed his Master's degree in Cultural Management at Thammasat University, Thailand in 2003. As a curator, Apisak Sonjod has participated in various projects in both local and international exhibitions. He was co-director of the exhibition *The Suspended Moment* by H&F Collection in 2006 and was selected as the Thai curator to present the Thai Pavilion at the *52nd Venice Biennale* in 2007. From 2008 until 2009, he co-curated the group exhibition *The Krungthep 226: The Art Exhibition from Early Days Bangkok to the Imagined Future* at Bangkok Art and Cultural Centre. He works with various genres in contemporary art and culture. Sonjod currently is the director of a community project entitled *A Stroll Through the Alleys Recalling the Legend of Promprab & Phanakorn, Bangkok*.

# ទឹកឡើងនៅទន្លេសាប
## លីម សុខចាន់លីណា

ទន្លេសាប និងបឹងទន្លេសាបនៅក្នុងប្រទេសកម្ពុជា មានទេសភាពប្រព័ន្ធបរិស្ថាននិងវប្បធម៌ផ្សេងៗដ៏សម្បូរបែប។ ទន្លេមេគង្គដែលហូរមកពីខ្ពង់រាបទឹកកកទីបេ និងឆ្លងកាត់ទំនាបអាស៊ីអាគ្នេយ៍ ផ្គត់ផ្គង់ទឹកនិងទទួលទឹកពីទន្លេសាបនិងបឹងទន្លេសាប។ ក្នុងកំឡុងពេលរដូវវស្សា នៅពេលទឹកទន្លេមេគង្គឡើងខ្ពស់បំផុត វាប្រសព្វជាមួយទន្លេសាបនៅចំកណ្តាលទីក្រុងភ្នំពេញ ដែលធ្វើឲ្យវាប្តូរទិសដៅ (ជាទន្លេតែមួយគត់នៅលើពិភពលោកដែលមានលក្ខណៈដូច្នេះ)និងហូរនាំទឹកទៅបឹងទន្លេសាបវិញ ដែលផ្គត់ផ្គង់ទឹកដល់ទំនាបលិចទឹកដែលនៅជាប់បឹង។

សម្រាប់ទិដ្ឋភាពទន្លេនៅក្នុងការផ្លាស់ប្តូរ ខ្ញុំបានធ្វើដំណើរឡើងចុះជាច្រើនលើកទៅទន្លេសាប ហើយបានស្នាក់នៅទីតាំងសំខាន់ៗជាមួយគ្រួសារនានាដោយម្តងៗមានរយៈពេលច្រើនថ្ងៃ។ ខ្ញុំបានចាប់ផ្តើមចាប់អារម្មណ៍ជាពិសេសទៅលើទិដ្ឋភាពចម្រុះដ៏អស្ចារ្យនៃទេសភាពទន្លេ និងត្រូវបានទាក់អារម្មណ៍ផងដែរពេលយល់ដឹងពីបាតុភូតសកល និងពាក្យ "បម្រែបម្រួលអាកាសធាតុ" និងពីរបៀបសម្របខ្លួនរបស់ប្រជាជនដែលរស់នៅលើឬនៅក្បែរទន្លេនោះ។

ដើម្បីផ្សំចំណាប់អារម្មណ៍ទាំងនេះជាមួយគ្នា ខ្ញុំបានសម្រេចចិត្តដាក់បន្ថែមបាតុភូតខុសធម្មតាសាមញ្ញមួយ នៅលើទេសភាពទន្លេគឺដុំទឹកកកអណ្តែតនៅក្នុងទឹកនៃអាកាសធាតុត្រូពិក។ រូបថតដែលបង្ហាញភាពស្ងប់ស្ងៀម និងប្លែកៗ ត្រូវបានថតដោយមានការជួយយ៉ាងច្រើនពីសហគមន៍នៅទីតាំងនីមួយៗ។ បរិស្ថានផុយស្រួយរបស់ពួកគេ គឺជាចម្រុះភាពនៃទីតាំងដុំទឹកកកឧស្សាហកម្មដែលរលាយនៅក្រោមកម្តៅព្រះអាទិត្យ និងធ្វើឲ្យទឹកទន្លេសាបឡើង។

លីម សុខចាន់លីណា កើតនៅខេត្តព្រៃវែង នៅឆ្នាំ ១៩៨៧។ គាត់គឺជាអ្នកថតរូបបែបឯកសារនិងគំនិត។ ជាញឹកញាប់ជាមួយការបង្កើតទិដ្ឋភាពដែលមានខ្លួនគាត់ជាតួសម្តែង គាត់ផ្តោតការយកចិត្តទុកដាក់ទៅលើការផ្លាស់ប្តូរផ្សេងៗនៃសង្គម វប្បធម៌ សេដ្ឋកិច្ច និងបរិស្ថាននៅក្នុងប្រទេសកម្ពុជាដែលជាលទ្ធផលនៃសកលភាវូបនីយកម្ម។ គាត់គឺជាសមាជិកស្ថាបនិកនៃក្រុមសិល្បករស្ទោវសិល្បៈ ដែលបានបង្កើតវិចិត្រសាលដែលផ្តោតតែលើការពិព័រណ៍ជាលើកដំបូងនៅទីក្រុងភ្នំពេញនៅឆ្នាំ ២០០៩ ឈ្មោះ វិចិត្រសាលសិល្បៈស-ស ព្រមទាំងកន្លែងដកបទពិសោធន៍ដែលដំណើរការដោយសិល្បករឈ្មោះ គម្រោងសិល្បៈស-សនៅឆ្នាំ ២០១០។ ការតាំងពិព័រណ៍ទោលរបស់គាត់រួមមាន "ម៉ូតូរបស់ខ្ញុំនិងខ្ញុំ" (រូបថតភ្នំពេញនៅចាវ៉ាកាហ្វេ ឆ្នាំ២០០៩) និង "កញ្ចប់អនាគត" (ស-សបាសាក់ ភ្នំពេញ ២០១២)។ គាត់បានចូលរួមនៅក្នុងការតាំងពិព័រណ៍ជាក្រុមជាច្រើននៅក្នុងប្រទេសកម្ពុជា ដែលរួមមាននៅសារមន្ទីរជាតិ និងនៅ ICAS សិង្ហបុរី និង មហោស្រពរូបថត Contact Photo Festival និង វិចិត្រសាលខាងកើត ក្រុងតូរ៉ុនតូ។

លីម សុខចាន់លីណា<br>
ទឹកឡើងនៅទន្លេសាប, ឆ្នាំ ២០១២<br>
៨០ x ១២០ cm<br>
៥ អ៊ីឌីស្យិន + AP

Lim Sokchanlina<br>
*Rising Tonle Sap*, 2012<br>
Series of five digital C-prints<br>
80 x 120 cm<br>
Edition of 5 + AP

# Rising Tonle Sap
## Lim Sokchanlina

The freshwater Tonle Sap River and Tonle Sap Lake in Cambodia have a rich landscape of various ecosystems and cultures. The Mekong River, which runs from the icy plateaus of Tibet through much of mainland Southeast Asia, feeds and is fed by the Tonle Sap River and Lake. During the monsoon season, when the Mekong is at its highest, it meets the Tonle Sap in the heart of Phnom Penh causing it to change direction – the only river in the world to do so – pushing water back to the great Tonle Sap Lake, which in turn feeds a dependent flood plain.

For *Riverscapes IN FLUX*, I took numerous trips up and down the Tonle Sap, and stayed at the select sites with families for many days at a time. I became particularly interested in the great visual diversity of the riverscape by also how to global phenomena and phrase "climate change" is understood and adapted to locally by the people living on or near the river.

To combine these interests, I decided to intervene on the riverscape with a humble, unnatural happening: ice floating in the waters of a subtropical climate. The quiet and fantastical photographs were staged with the great help form the communities in each location. Their fragile surroundings are the variances in my compositions of industrial ice melting under the hot sun, rising the Tonle Sap.

Lim Sokchanlina, born in Prey Veng in 1987, is a photographer working across documentary and conceptual practices. Often staging scenarios involving himself as a protagonist, he calls attention to a variety of social, cultural, economic and environmental changes in Cambodia resulting from globalization. He is founding member of the artist collective Stiev Selapak / Art Rebels, which founded the first exhibition-dedicated gallery in Phnom Penh in 2009, Sa Sa Art Gallery, as well as the first artist-run experimental space, Sa Sa Art Projects, in 2010. His solo exhibitions include *My Motorbike and Me* (PhotoPhnomPenh at Java Café, 2009) and *Wrapped Future* (SA SA BASSAC, Phnom Penh, 2012). Lim has exhibited widely in group exhibitions across Cambodia, incuding at the National Museum, and at ICAS, Singapore and *Contact Photo Festival* and The East Gallery, Toronto.



# រង្វង់ខ្មៅ
## លួងហ៊ូ ទ្រីញ

ខ្ញុំគិតអំពីទីក្រុង និងព្រៃឈើ ហើយតាមរយៈការគិតនេះ នាំឲ្យខ្ញុំគិតដល់ទន្លេផងដែរ។ របស់ទាំងបីនេះ មានទំនាក់ទំនងជាមួយគ្នាទៅវិញទៅមក។

កម្មវត្ថុនៃស្នាដៃសិល្បៈរបស់ខ្ញុំគឺ ទន្លេក្រហម ដែលជាទន្លេធំបំផុតទីពីរនៅក្នុងប្រទេសវៀតណាម ដែលមានប្រភពមកពីប្រទេសចិន និងហូរចូលទៅក្នុងប្រទេសវៀតណាមតាមរយៈខេត្ត Lao Cai។ ទន្លេនេះ ជាឆ្អឹងនិងសាច់ឈាមនៃជីវិតរបស់ប្រជាជនវៀតណាម និងជាសក្ខីភាពនៃប្រវត្តិសាស្ត្ររាប់ពាន់ឆ្នាំ ដែលកំពុងបង្ហាញនូវក្តីតប់ប្រមល់ខុសប្រក្រតីកាន់តែខ្លាំងឡើងៗ។ ពណ៌របស់វាបាននិងកំពុងប្រែប្រួលរហូត កម្រិតទឹកនិងដីល្បាប់កំពុងថយចុះ ហើយការបំពុលដ៏ធ្ងន់ធ្ងរបានធ្វើឲ្យវាប្រែក្លិនជាអាក្រក់...។ ទន្លេនេះកំពុងប្រឈមនឹងការបំផ្លាញ។ ក្លិន រូបភាព និងបាតុភូតចម្លែកៗ កំពុងកើតមានកាន់តែច្រើនឡើងៗពីព្រំដែនម្ខាងទៀត។

គម្រោងរូបថតរបស់ខ្ញុំ គឺជាការសិក្សាស្រាវជ្រាវបន្តពីឆ្នាំ ២០០៩ របស់ខ្ញុំអំពីផ្នែកនានានៃទន្លេក្រហមដែលហូរកាត់ទីក្រុងហាណូយ ជាមួយនឹងសេរីរូបថត "អារម្មណ៍ដឹងមុន" ខណៈពេលដែលទន្លេបានរីងស្ងួតដល់បាត។ គម្រោងនេះបានផ្តល់ឱកាសសម្រាប់ឲ្យខ្ញុំធ្វើការសង្កេតមើលទន្លេពីទីដែលវាចាប់ផ្តើមនៅក្នុងខេត្ត Lao Cai និង ហូរឆ្លងកាត់ខេត្តក្រុងនានា មុននឹងហូរចូលទៅក្នុងសមុទ្រនៅ Thai Binh និងតំបន់មាត់សមុទ្រ Nam Dinh។ ខ្ញុំសង្ឃឹមថា រូបភាពបែបពញ្ញាក់អារម្មណ៍ទាំងនេះ និងដែលផ្ទុយគ្នាទាំងស្រុងជាមួយនឹងការចងចាំនិងការស្រមៃរបស់ប្រជាជនអំពីទន្លេក្រហម នឹងបណ្តាលឲ្យយើងទាំងអស់គ្នាចោទជាសំណួរនិងប្រដេញគំនិតគ្នា។

លួងហ៊ូ ទ្រីញ កើតនៅក្នុងឆ្នាំ ១៩៨៥ ហើយបច្ចុប្បន្ននេះកំពុងរស់នៅនិងធ្វើការនៅទីក្រុងហាណូយ។ ពីឆ្នាំ ១៩៩៨ ដល់ឆ្នាំ ២០១០ នាងបានសិក្សាឧបករណ៍តន្ត្រីមានខ្សែ នៅសភាតូរ្យតន្ត្រីជាតិរបស់វៀតណាម។ នាងធ្លាប់បានទទួលបានអាហារូបករណ៍យ៉ាម៉ាហា សម្រាប់ស្នាដៃឆ្នើមរបស់ខ្លួន។ ចាប់តាំងពីបញ្ចប់ការសិក្សា និងជ្រើសរើសយកជំនាញតន្ត្រីហ្វ្រាស់ប្រើឧបករណ៍មានខ្សែនៅក្នុងឆ្នាំ ២០១០ រួចមក នាងបាននិងកំពុងធ្វើការជាសិល្បករឯករាជ្យមួយរូបលើផ្នែកតន្ត្រីអេឡិកត្រូនិកនិងតន្ត្រីសហសម័យ។ នាងបានសម្តែងនៅក្នុងមហោស្រពក្នុងស្រុកមួយចំនួននៅក្នុងទីក្រុងហាណូយ ដូចជាមហោស្រព Hanoi Sound Stuff Festival (២០១០, ២០១១) និងមហោស្រព Cau Am Thanh Festival ជាដើម។

លួងហ៊ូ ទ្រីញ
រង្វង់ខ្មៅ, ឆ្នាំ ២០១២
ការតម្លើងសំលេង, ប្រអប់ពន្លឺ, អត្ថបទ

Luong Hue Trinh
*Black Circle*, 2012
Sound installation, lightboxes, text

# Black Circle
## Luong Hue Trinh

I think about the cities and forests. And by doing so, also about rivers. The three are interwoven.

The object of my artwork is the Red River, the second largest river in Vietnam that rises from China and flows into Vietnam through Lao Cai province. Flesh and bone of the life of Viet people, witness of a history of thousands of years, the river is increasingly showing unusual sighs. Its color has been changing constantly, the water and silt levels are decreasing, and severe pollution has turned its smell into an unpleasant one… The river is at risk of being killed. The strange smell, images and phenomena are increasingly coming from the other side of the border.

My photo project is a continuum of my 2009 research of the parts of the Red River that run through Hanoi with the photo series 'Predictive Feeling' as the river became dry to its bed. The project provided an opportunity for me to observe the river from where it begins in Lao Cai through cities and provinces before it flows in the sea in Thai Binh – Nam Dinh sea mouth. I hope the somewhat shocking images, totally in contrast with people's memories and imagination of the Red River will provoke each and every one of us to question and challenge.

Loung Hue Trinh was born in 1985 and is currently living and working in Hanoi. From 1998 until 2010, studied keyboard at the Vietnam National Music Academy. She has been awarded the Yamaha Scholarship for her outstanding accomplishments. Since completing her studies and majoring in Jazz Keyboard in 2010, Luong Hue Trinh has been working as a freelance artist for electronic and contemporary music. She has performed in a number of local festivals in Hanoi, such as *Hanoi Sound Stuff Festival* (2010, 2011) and *Cau Am Thanh Festival*.



# មេកានិកមេគង្គ
## ផាន់ថៅ ង្វៀន

គំនិតរបស់ខ្ញុំសម្រាប់គម្រោងនេះ បានវិវត្តឡើងកាលពីរដូវក្តៅឆ្នាំមុន នៅពេលខ្ញុំបានទៅដែនដីសណ្តរ Cuu Long នៅវៀតណាមខាងត្បូង និងទស្សនារោងចក្រត្រីអណ្តែងនៅក្នុងតំបន់ឧស្សាហកម្មមួយ។ ពេលចូលទៅក្នុងរោងចក្រ ខ្ញុំត្រូវលាងដៃ ពាក់របាំងមុខ និងស្លៀកសម្លៀកបំពាក់ការពារ។ ភាពចម្លែកនៃរោងចក្របានធ្វើឲ្យខ្ញុំកាន់តែភ្ញាក់អារម្មណ៍ចំពោះក្លិននិងបរិយាកាសដែលនៅជុំវិញខ្លួន។ បទពិសោធន៍ពិតមានលក្ខណៈខុសប្លែកយ៉ាងខ្លាំងពីដែនដីសណ្តរមេគង្គដែលគេផ្សព្វផ្សាយនៅក្នុងសៀវភៅមគ្គុទ្ទេសន៍និងភាពយន្តឯកសារ ដែលតែងតែផ្សព្វផ្សាយថាទន្លេនេះមានលក្ខណៈស្រស់ស្អាត និងជាទីស្វាគមន៍បែបធម្មជាតិ។ តាមការពិតដែនដីសណ្តរនេះ មិនមានភាពស្ងប់សុខរហូតឡើយ ប៉ុន្តែវាគឺជាកន្លែងមួយដែលមានប្រវត្តិរឿងរ៉ាវ និងរឹករវជាច្រើន។ ការនេះបណ្តាលឲ្យខ្ញុំមានទឹកចិត្តកាន់តែខ្លាំងក្លាក្នុងការរុករកភាពស្មុគស្មាញរបស់តំបន់នេះ ដែលមានអត្ថន័យផ្ទាល់ខ្លួន និងសង្គមសម្រាប់ខ្ញុំ។ គម្រោងនេះ បន្តក្តីកង្វល់របស់ខ្ញុំ ជាមួយទំនាក់ទំនងស្រពិចស្រពិលចំពោះប្រវត្តិសាស្ត្រ ការចងចាំផ្ទាល់ខ្លួន កាយវិការ ការរៀបចំជាផ្លូវការ និងទិដ្ឋភាពបែបលន្លង់លន្លោច។

ផាន់ថៅ ង្វៀន កើតនៅឆ្នាំ១៩៨៧ នៅក្នុងទីក្រុងហូជីមិញ ប្រទេសវៀតណាម។ នាងបានសិក្សានៅសាកលវិទ្យាល័យវិចិត្រសិល្បៈក្រុងហូជីមិញ ហើយកំពុងបន្តសិក្សាថ្នាក់អនុបណ្ឌិតវិចិត្រសិល្បៈនៅសាលាវិទ្យាស្ថានសិល្បៈ Chicago។ នាងធ្លាប់តាំងពិព័រណ៍នៅក្នុងប្រទេសវៀតណាម សិង្ហបុរី និង Chicago។ ការតាំងពិព័រណ៍សំខាន់ៗមានដូចជា៖ "វៀតណាមប្រសព្វគ្នា៖ ស្នាដៃថ្មីពីខាងជើងនិងខាងត្បូង" ដែលត្រូវបានរៀបចំដោយ Iola Lenzi នៅឯវិចិត្រសាល Valentine Willie Fine Art នៅប្រទេសសិង្ហបុរី និងប្រទេសម៉ាឡេស៊ី, "Ket Noi" នៅសារៈមន្ទីរសិល្បៈសិង្ហបុរី, ស្នាដៃមួយនៅមហោស្រពសិល្បៈសម្តែងអន្តរជាតិនីប៉ុន (Nippon International Performance Art Festival) នៅប្រទេសជប៉ុន, និងការពិព័រណ៍និក្ខេបបទថ្នាក់អនុបណ្ឌិតវិចិត្រសិល្បៈនៅវិចិត្រសាល Sullivan Gallery នៅ Chicago។ នាងបានទទួលរង្វាន់និងជំនួយឧបត្ថម្ភជាច្រើន ដែលរួមមានទាំងអាហារូបករណ៍ប្រធានាធិបតី នៃសាលាវិទ្យាស្ថានសិល្បៈ Chicago។ ស្នាដៃរបស់នាង បានឈ្នះរង្វាន់ទីមួយនៅក្នុងការប្រកួតសិល្បៈចក្ខុទស្សន៍របស់សម្ព័ន្ធសហជីព (Union League Visual Art Competition) នៅ Chicago ឆ្នាំ២០១១។

ផាន់ថៅ ង្វៀន
មេកានិកមេគង្គ, ឆ្នាំ ២០១២
វីដេអូចំនួន ១, រយៈពេល ១៨ នាទី

Phan Thao Nguyen
*Mekong Mechanical*, 2012
Single-channel video, 18 minutes

# Mekong Mechanical
## Phan Thao Nguyen

My idea for the project evolved last summer when I went to the Cuu Long delta in South Vietnam and visited catfish factories in an industrial zone. Entering the factory, I had to wash my hands, war a mask and put n a protective suit. The peculiarity of the factory setting made me more sensitive to the smell and the atmosphere surrounding me. The real experience was so different from the version of the Mekong delta popularized in guidebooks and documentaries, which always promote the river as beautiful and welcoming in nature. In reality, the delta is not always calm and placid, but a place with diverse and turbulent history. This leads me to great aspiration to explore the complexity of the region which for me carries personal and social meaning. The project continues my concern with the ambiguous relationship to history, personal memory, gesture, formal arrangement and poetic imagery.

Phan Thao Nguyen was born in 1987 in Ho Chi Minh City, Vietnam. She studied at Ho Chi Minh University of Fine Arts and is currently pursuing her MFA at the School of the Art Institute of Chicago. She exhibited in Vietnam, Singapore and Chicago. Selected exhibitions include: *Intersection Vietnam: New Works from North and South*, curated by Iola Lenzi, at Valentine Willie Fine Art in Singapore and Malasia; *Ket Noi* at the Singapore Art Museum; a performance at the *Nippon International Performance Art Festival*, Japan and her MFA Thesis Exhibition at Sullivan Gallery, Chicago. She received numerous awards and grants including the Presidential Scholarship, School of the Art Institute of Chicago. Her work won the first prize at the Union League Visual Art Competition, Chicago 2011.



# ផ្លូវរបស់ជីតាខ្ញុំត្រូវបានឃាំងជារៀងរហូត

## ស៊ូធីរ៉ាត់ ស៊ូប៉ាប៉ារិនយ៉ា

ទន្លេពីង( Ping River ) គឺជាផ្លូវប្រវត្តិសាស្ត្រមួយសម្រាប់ការនាំចេញឈើម៉ៃសាក់សម្រាប់ពាណិជ្ជកម្មសៀម-អឺរ៉ុប និងជាផ្នែកសំខាន់មួយរបស់ប្រវត្តិគ្រួសាររបស់ខ្ញុំផងដែរ។ ជីដូនជីតារបស់ខ្ញុំស្រឡាញ់ទន្លេពីង។ វាគឺជាស្រុកកំណើតរបស់ពួកគាត់ ការងាររបស់ពួកគាត់ និងជីវិតរបស់ពួកគាត់។ ជីតាខាងម្តាយរបស់ខ្ញុំគឺជាប្រធានគ្រប់គ្រងការដឹកជញ្ជូនឈើ ដែលដឹកជញ្ជូនឈើម៉ៃសាក់ពីខេត្តឈៀងម៉ៃទៅទីក្រុងបាងកក។ យើងមិនសូវដឹងពីជីវិតរបស់គាត់ទេ ព្រោះពេលនោះគាត់ត្រូវចំណាយពេលជាង ៣ខែ ដើម្បីបំពេញការងាររបស់គាត់។ វាគឺជាការងារដែលមានគ្រោះថ្នាក់ ព្រោះគាត់ត្រូវប្រើដំរីដើម្បីដឹកជញ្ជូនឈើហ៊ុបធ្ងន់ ប្រឈមប្រឋាននឹងចោរ និងត្រូវធ្វើដំណើរចន្លោះផ្ទាំងថ្មខ្ពស់ចោតក្រហេងក្រហូង។ ខ្ញុំបានដើរតាមផ្លូវរបស់ជីតារបស់ខ្ញុំ ប៉ុន្តែបានតែផ្នែកខាងលើប៉ុណ្ណោះ គឺចាប់ពីទំនប់ទឹកភូមីបុលនៅក្នុងខេត្តតាក់ ខេត្តឡាំភុន និងខេត្តឈៀងម៉ៃប៉ុណ្ណោះ។ ទិដ្ឋភាពទន្លេក្នុងជំនាន់គាត់ និងជំនាន់ខ្ញុំ មានការខុសប្លែកគ្នាទាំងស្រុង ដោយការផ្លាស់ប្តូរចាប់ផ្តើមមានបន្ទាប់ពីទំនប់ទឹកត្រូវបានសាងសង់នៅក្នុងឆ្នាំ ១៩៥៨។ ទឹកទន្លេត្រូវទប់ ហើយផ្លូវដឹកជញ្ជូនត្រូវបានអភិវឌ្ឍបន្ថែម… ដំណើរកំសាន្តតាមដងទន្លេពីង និងដំណើរកំសាន្តតាមទូក បានជួយឲ្យខ្ញុំយល់ពីអ្វីដែលជីតារបស់ខ្ញុំធ្លាប់ឆ្លងកាត់កាលពីមុន ព្រមពេលជាមួយគ្នានេះផងដែរ ខ្ញុំបានអាចសង្កេតពីបញ្ហាផ្សេងៗទៀតដែលកើតឡើងនៅក្នុងជំនាន់របស់ខ្ញុំ។ នៅក្នុងស្នាដៃតម្លើងនេះ គឺជាខ្សែវីដេអូចំនួន ២ ដែលខ្ញុំបានថតក្នុងកំឡុងពេលដែលខ្ញុំធ្វើដំណើរ។ វីដេអូនៅខាងស្តាំ គឺជាវីដេអូឯកសារមួយអំពីការធ្វើដំណើរតាមផ្លូវទឹកនៅលើបឹង នៅផ្នែកខាងលើទំនប់ទឹកភូមីបុល ជាទីដែលទន្លេពីងពីមុនត្រូវពង្រីកដើម្បីបានជាបឹងដ៏ធំមួយ។ សព្វថ្ងៃនេះ ភូមិនិងព្រៃម៉ៃសាក់ពីមុនៗជាច្រើន ត្រូវលិចនៅក្រោមទឹកនៅក្នុងតំបន់នេះ។ វីដេអូខាងឆ្វេង បង្ហាញពីទំនប់ទាបចំនួន ១៣ ទ្វារទឹក និងទំនប់ទឹកភូមីបុលផ្ទាល់ នៅបន្តបន្ទាប់គ្នាចាប់ពីទំនប់ទាបទីមួយនៅជិតប្រភពរបស់ទន្លេមកដល់ទំនប់ទឹកភូមីបុល។

ស៊ូធីរ៉ាត់ ស៊ូប៉ាប៉ារិនយ៉ា គឺជាសិល្បករផ្នែកវីដេអូនិងស្នាដៃបែបតម្លើង។ នាងកើតនៅក្នុងឆ្នាំ ១៩៧៣។ នាងចូលចិត្ត និងធ្វើការនៅក្នុងខេត្តឈៀងម៉ៃ ប្រទេសថៃ។ បន្ទាប់ពីទទួលបានបរិញ្ញាប័ត្រវិចិត្រសិល្បៈខាងគំនូរពីមហាវិទ្យាល័យវិចិត្រសិល្បៈនៅសាកលវិទ្យាល័យឈៀងម៉ៃរួចមក នាងបានទទួលសញ្ញាប័ត្រកម្រិតក្រោយឧត្តមសិក្សា ផ្នែកសិល្បៈរូបភាពនិងសម្លេង នៅសាលា Hochshule für Grafik und Buchkunst ក្នុងទីក្រុង Leipzig ប្រទេសអាល្លឺម៉ង់។ ការតាំងពិព័រណ៍ជាលក្ខណៈអន្តរជាតិរបស់នាង មានដូចជាកម្មវិធីតាំងពិព័រណ៍ How Physical ( នៅសារមន្ទីររូបថតក្រុងតូក្យូ ឆ្នាំ២០១១ ), Koganecho Bazaar ឆ្នាំ២០១១, សំបុត្រត្រឡប់ថៃ-អាល្លឺម៉ង់ ( នៅមជ្ឈមណ្ឌលសិល្បៈនិងវប្បធម៌បាងកក ឆ្នាំ២០១០ ) និងទិដ្ឋភាពពីកន្លែងផ្សេងទៀត ( នៅវិចិត្រសាលសិល្បៈ Queensland ឆ្នាំ២០០៩ )។ ជាមួយជំនួយពីអាហារូបករណ៍ក្រុមប្រឹក្សាវប្បធម៌អាស៊ីមួយនៅក្នុងឆ្នាំ ២០១១ នាងបានស្នាក់នៅទីក្រុងញូយ៉ក និងសិក្សាស្រាវជ្រាវពីសិល្បៈចក្ខុទស្សន៍ និងភាពយន្តពិសោធន៍។
www.atelierorange.info

ស៊ូធីរ៉ាត់ ស៊ូប៉ាប៉ារិនយ៉ា
ផ្លូវរបស់ជីតាខ្ញុំត្រូវបានឃាំងជារៀងរហូត, ឆ្នាំ ២០១២
វីដេអូចំនួន ២, រយៈពេល ១៣ នាទី

Sutthirat Supaparinya
*My Grandpa's Route Has Been Forever Blocked*, 2012
Two-channel video, 13 minutes

# My Grandpa's Route Has Been Forever Blocked
## Sutthirat Supaparinya

The Ping River a historical route for teakwood export, Siamese-European trade and also an important part of my family's history. My grandparents loved along the Ping River. It was their hometown, their work and their life. My maternal grandfather was chief manager for the timber transport that moved teakwood from Chiang Mai to Bangkok. His life was mysterious to us, since it took him more than 3 months to complete his job. It was dangerous work as he had to handle elephants and heavy logs, keep in eye out for bandits and navigate between crags and cliffs. I followed my grandfather's route, but only upstream from the Bhumibol Dam in the Tak, Lamphun and Chiang Mai provinces. The riverscape of his time and mine are completely different having changed after the Bhumibol Dam was built in 1958, the river was blocked and the transportation route was developed further… Journeys along Ping River as well as a boat trip helped me to understand what my grandfather experienced in the past; at the same time I could observe other issues that have arisen in my time. In this installation are 2 channel videos I captured during my trip. In this installation are 2 channel videos that I captured during my trip. The right one is a documentary about the cruise on the lake above Bhumibol Dam where the previous Ping River was expanded to become a huge lake. Today many former villages and teak forests are underwater in this area. The left video shows 13 weirs, floodgates and the dam itself, sequentially from the first weir near the origin of the river to the Bhumibol Dam.

Sutthirat Supaparinya is a video and installation artist. Born in 1973, she loves and works in Chiang Mai, Thailand. After earning a BFA in Painting from the Faculty if Fine Arts at Chaing Mai University, she received a Postgraduate degree in Media Arts at the Hochshule für Grafik und Buchkunst in Leipzig, Germany. Her international exhibitions include *How Physical* (Tokyo Metropolitan Museum of Photography 2012) Koganecho Bazaar 2011, *Return Ticket Thanland-Germany* (Bangkok Art and Culture Centre, 2010), and The *View from Elsewhere* (Queensland Art Gallery, 2009). With assistance from an Asian Cultural Coucil fellowship in 2011, she resided in New York researching the visual arts and experimental films. www.atelierorange.info



# ទំនាបកណ្ដាល

## ថន សុខ

នៅក្នុងការងារស្រែចម្ការ កសិករបង្កើតរូបសំណាកមួយ និងដាក់ឲ្យរូបនោះឈរនៅក្នុងវាលស្រែ ដើម្បីជាមធ្យោបាយបន្លាចនិងបណ្ដេញសត្វដែលគម្រាមកំហែងដល់ដំណាំរបស់ខ្លួន។ នៅក្នុងប្រទេសកម្ពុជាគេហៅរូបនោះថា ទីងមោង។ កសិករប្រើចម្បើងស្ងួតដើម្បីធ្វើរូបទីងមោងរាងដូចមនុស្សហើយយកសម្លៀកបំពាក់ចាស់ៗរបស់ខ្លួនពាក់ឲ្យវា។ នៅរដូវប្រាំង គេដាក់ទីងមោងឈរនៅលើដីដោយទល់ដោយបង្គោលឬស្សីឬឈើ ប៉ុន្តែពេលទឹកជន់លិចក្នុងរដូវវស្សាធ្វើឲ្យទីងមោងឈរតែម្នាក់ឯងក្នុងផ្ទៃដីច្រើនហិកតាដើម្បីការពារដី ហើយគ្មានសត្វណាអាចបំផ្លាញដំណាំរបស់ពួកគេឡើយ ព្រោះអីគ្មានដំណាំ។

ការជន់លិចទន្លេនិងដីនៅក្នុងឆ្នាំ២០១១ បានបង្កឲ្យកសិករនិងគ្រួសារជាច្រើនគ្មានការងារ និងចំណីអាហារ ហើយបានបំផ្លាញផ្ទះសម្បែង និងជីវភាពរស់នៅជាច្រើន។ គ្រួសាររបស់ខ្ញុំដែលមានសមាជិកចំនួន ១០ នាក់ រស់នៅលើច្រាំងទន្លេសាបនៅភាគខាងត្បូងនៃទីក្រុងភ្នំពេញ។ ក្នុងកំឡុងពេលទឹកជំនន់ ជាន់ផ្ទាល់ដីផ្ទះរបស់ខ្ញុំត្រូវបានទឹកជន់លិចទាំងស្រុង ហើយទុកឲ្យខ្ញុំនិងគ្រួសារខ្ញុំរស់នៅ ញាំ និង គេងជាមួយគ្នា នៅលើដំបូលផ្ទះអស់រយៈពេលជាច្រើនខែ។

សម្រាប់ទិដ្ឋភាពទន្លេនៅក្នុងការផ្លាស់ប្ដូរ ខ្ញុំបានចំណាយពេលជាមួយកសិករនៅក្នុងខេត្តតាកែវដែលជាស្រុកកំណើតរបស់ខ្ញុំ ដើម្បីរៀនពីរបៀបធ្វើរូបទីងមោង។ ពេលនោះ ខ្ញុំអាចធ្វើបានរូបចំនួន ១០ ដើម្បីតំណាងឲ្យគ្រួសាររបស់ខ្ញុំ ហើយខ្ញុំបានវាស់កម្ពស់ឲ្យត្រូវនឹងកម្ពស់របស់ពួកយើង និងពាក់សម្លៀកបំពាក់របស់យើងឲ្យវា។ ដោយបានរៀបឡើងវិញដូចពេលទឹកជំនន់ គ្រួសារយើងរង់ចាំ សម្របសម្រួល ចោទសួរពីប្រយោជន៍ អំណាច ការទទួលយក និងក្ដីសង្ឃឹម។

ថន សុខ កើតនៅខេត្តតាកែវ ប្រទេសកម្ពុជា នៅឆ្នាំ ១៩៨៤។ គាត់តែងអង្កេតពីជំនឿ សម្ភារៈ និង ពិធីដែលមានលក្ខណៈសាសនានិងវិញ្ញាណ តាមរយៈចម្លាក់ ការតម្លើងវីដេអូ និងការសម្ដែង។ គាត់បានបញ្ចប់ការសិក្សាពីសាលាសិល្បៈរ៉ែយំនៅឆ្នាំ ២០០៥ និងបានចូលរួមក្នុងសិក្ខាសាលារ៉ែយំនៅឆ្នាំ ២០០៧ ដែលក្នុងកំឡុងពេលនោះ គាត់បានសហការជាមួយសិល្បករជាភ្ញៀវមួយចំនួនដែលរួមមាន ចាន់ លួង (វៀតណាម) និងសិល្បករមួយក្រុមដែលមានមូលដ្ឋាននៅទីក្រុងហាណូយ និងជាមួយសិល្បករជប៉ុន អេកូនិងកូម៉ា ហើយបានធ្វើដំណើរទៅសហរដ្ឋអាមេរិកនិងតៃវ៉ាន់ជាមួយពួកគេសម្រាប់ការសម្ដែង “រឿងរ៉ាវកម្ពុជា (Cambodia Stories)”។ សព្វថ្ងៃនេះគាត់កំពុងសិក្សាផ្នែកស្ថាបត្យកម្មនៅកម្ពុជា។ ការតាំងពិព័រណ៍ទោលរបស់គាត់រួមមាន “ពន្លឺនៃព្រះនេត្រព្រះ” នៅស-សបាសាក់ (២០១២) និង “សោកនាដកម្ម” (២០០៩)។ ការតាំងពិព័រណ៍ជាក្រុមសំខាន់ៗរួមមាន “តាំងពីដើមមកដល់បច្ចុប្បន្ន” នៅវិចិត្រសាល 10 Chancery Lane Gallery ហុងកុង (២០០៩) និង “វីដេអូ៖ សិល្បៈនិងប្រវត្តិសាស្ត្រ” នៅសារៈមន្ទីរសិល្បៈសិង្ហបុរី (២០១១)។ ថន សុខ ធ្លាប់ជាសិល្បករធ្វើការនិងស្នាក់នៅ Tokyo Wonder Site, ក្រុង Aoyama (២០០៥) និងនៅ S-AIR, ក្រុង Sapporo (២០១១)។

ថន សុខ
ទំនាបកណ្ដាល, ឆ្នាំ ២០១២
ការតម្លើងវីដេអូ, ចំបើង, ក្រណាត់, ស៊ីម៉ង់ត៍

Than Sok
*Middle Ground*, 2012
Video installation, hay, clothing, cement

# Middle Ground
## Than Sok

In most agrarian cultures, farmers create a figure to stand in the fields as a way of scaring away animals that threaten their crops. In Cambodia, we call this figure dtingmong. Farmers used dried paddy straw to create a scarecrow shaped like a human being and clothe it with their old clothes. In the dry season, the dtingmong stands on land, supported by a bamboo or wooden pole, but in the rainy season flooding makes the dtingmong stand alone for hectares, watching over the land, but in vain; there is no animal that can harm their crops because there are no crops.

The 2011 flooding of the rivers and land left so many farmers and families without work and food, and has destroyed homes and livelihoods. My family of ten lives on the banks of the Tonle Sap River in southern Phnom Penh. During the floods, the ground floor of our house was flooded totally, leaving us to live, eat, and sleep together on the our roof for months.

For *Riverscapes IN FLUX*, I spent time with farmers in Takeo province – my homeland – to learn how to make dtingmong. I then could create ten figures to represent my family and I – measured to our heights and earing our clothes. Restaged in flood, together we wait, compromise, question usefulness, power, acceptance and hope.

Than Sok, born in Takeo, Cambodia in 2984, investigates religious and spiritual beliefs, materials and rituals through sculpture, installation, video and performance. He graduated from Reyum Art School in 2005 and attended the Reyum Workshop in 2007, during which he collaborated with a number of visiting artists including Tran Luong (Vietnam) and a group of Hanoi-based artists, and Eiko and Koma, with whom he toured the United States and Taiwan for the performance "Cambodia Stories". Than Sok is currently studying architecture in Cambodia. His solo exhibitions include *The Halo of the Omnipresent Eye*, SA SA BASSAC (2012) and *Tragedy* (2009). Selected group exhibitions include *Forever Until Now*, 10 Chancery Lane Gallery, Hong Kong (2009) and *Video: An Art, A History*, Singapore Art Museum (2011). Than Sok was a resident at Tokyo Wonder Site, Aoyama (2005) and at S-AIR: Sapporo Artists in Residence, Sapporo (2011).



# ឡើងនិងស្រក រះនិងលិច
## វុធ លីណូ

កំពង់ភ្លុក គឺជាឈ្មោះសហគមន៍ព្រៃលិចទឹកមួយដែលនៅជាប់បឹងទន្លេសាប។ សម្រាប់ទិដ្ឋភាពទន្លេនៅក្នុងការផ្លាស់ប្តូរ ខ្ញុំបានស្នាក់នៅរយៈពេលមួយសប្តាហ៍ជាមួយគ្រួសារមួយដ៏រាក់ទាក់ កក់ក្តៅ និងមានសន្តានចិត្ត នៅក្នុងសហគមន៍នេះ ដែលជាមធ្យោបាយមួយដើម្បីចាប់ផ្តើមយល់ដឹងពីទំនាក់ទំនងរបស់ប្រជាជនជាមួយទន្លេ និងភាពពឹងផ្អែករបស់ពួកគេទៅលើទន្លេ។ អ្វីដែលបានធ្វើឲ្យខ្ញុំចាប់អារម្មណ៍នាពេលនោះ គឺថាប្រព័ន្ធសំណង់ផ្ទះដែលសង់លើសសរផុតដីខ្ពស់ៗដូចៗគ្នា និងការសម្របទៅតាមការជន់លិចដោយធម្មជាតិជារៀងរាល់ឆ្នាំនៅក្នុងរដូវវស្សា។ នៅរដូវវស្សានេះ ទន្លេសាបត្រូវបានចរន្តទឹកទន្លេមេគង្គហូរចូលធ្វើឲ្យផ្លាស់ប្តូរទិសដៅម្ល៉ោះហើយវាផ្តល់ទឹកទៅឲ្យវាលទំនាបលិចទឹកដែលនៅជុំវិញបឹងទន្លេសាប។ ក្នុងកំឡុងពេលទឹកជំនន់ឆ្នាំ ២០១១ កំពង់ភ្លុកបានទទួលរងគ្រោះ ប៉ុន្តែបានអាចទប់ទល់នឹងកម្រិតទឹកជន់ "ធ្ងន់ធ្ងរជាងធម្មតា" ដោយសារសមត្ថភាពអាចបត់បែនបានប្រសើរជាងសហគមន៍ជាច្រើនទៀតនៅជុំវិញនោះ។ ខ្ញុំបានចាប់អារម្មណ៍ផងដែរចំពោះទំនាក់ទំនងជ្រាលជ្រៅរបស់សហគមន៍ចំពោះអ្នកតា ជាវិញ្ញាណធម្មជាតិដែលមានសព្វទីកន្លែងដែលអាចផ្តល់នូវការរស់នៅសុខសាន្តជាមួយព្រៃឈើនិងទន្លេ។ ការតម្លើងរូបកូនខ្ទមរបស់ខ្ញុំ តំណាងឲ្យទាំងរចនាសម្ព័ន្ធសាមញ្ញនៃផ្ទះរបស់ពួកគេ និងខ្ទមអ្នកតា។ នៅក្នុងស្នាដៃនេះ គេអាចស្តាប់ឮសូរនូវទិដ្ឋភាពទន្លេនៅភូមិកំពង់ភ្លុក ដែលជាស្រទាប់សម្លេងជាច្រើនមកពីការរស់នៅប្រចាំថ្ងៃរបស់ប្រជាជនជាមួយទឹក ការនេសាទ ការនិទានរឿង និងការប្រារព្ធពិធីសម្រាប់អរក្ខអ្នកតានៅទន្លេ។

វុធ លីណូ កើតនៅទីក្រុងភ្នំពេញនៅឆ្នាំ ១៩៨២។ គាត់ធ្វើការភាគច្រើនជាមួយរូបថត និងសំលេង ហើយចាប់អារម្មណ៍ទៅលើគំនិតជុំវិញការប្រែប្រួលសង្គម និងការរីកចម្រើនរបស់ប្រទេសជាតិនៅកម្ពុជា។ គាត់បានទទួលបរិញ្ញាប័ត្រផ្នែកពត៌មានវិទ្យានៅក្នុងឆ្នាំ ២០០២ និង សញ្ញាប័ត្រថ្នាក់អនុបណ្ឌិតផ្នែកវិទ្យាសាស្ត្រសង្គមនៅក្នុងឆ្នាំ ២០០៩ នៅសាកលវិទ្យាល័យ RMIT នៅប្រទេសអូស្ត្រាលី។ គាត់គឺជាសមាជិកស្ថាបនិកមួយរូបរបស់ក្រុមសិល្បករស្វាវសិល្បៈ និងជាប្រធានគម្រោងសិល្បៈស-ស នៅទីក្រុងភ្នំពេញ។ គាត់បានរៀបចំកម្មវិធីពិព័រណ៍ និងព្រឹត្តិការណ៍ជាច្រើននៅក្នុងប្រទេសកម្ពុជា ហើយថ្មីៗបំផុតនេះគឺកម្មវិធីពិព័រណ៍ "បន្ទប់សំលេង" ដោយសហការជាមួយ Incidental ប្រទេសអង់គ្លេស។ កម្មវិធីពិព័រណ៍ជាក្រុមរបស់គាត់ រួមមាន "១៤+១" (២០០៧) និង "ទេវតាពណ៌ខៀវ (Blue Angels)" (២០០៨) ដែលកម្មវិធីពិព័រណ៍ទាំងពីរនេះត្រូវបានរៀបចំធ្វើនៅវិចិត្រសាលមជ្ឈមណ្ឌលវប្បធម៌បារាំងក្នុងរាជធានីភ្នំពេញ និងកម្មវិធីពិព័រណ៍ទោល "ធម្មតា" (ស-សបាសាក់ ២០១១)។

វុធ លីណូ
ឡើងនិងស្រក រះនិងលិច, ឆ្នាំ ២០១២
សំលេង ចំនួន ២, ដែក, ឈើ

Vuth Lyno
*Rise and Fall*, 2012
Metal, wood, two-channel sound

# Rise and Fall
## Vuth Lyno

Kompong Pluk is the name of a flooded forest community based on the Tonle Sap River. For Riverscapes IN FLUX, I did a week-long residency with a warm, hospitable and generious family in this community as a way to begin to understand the people's relationship with and dependency on the river, What interested me was this community's modular and uniquely high stilled housing system that accommodates the natural annual flooding in the rainy season. At this time, the Tonle Sap is forced by the Mekong's current to reverse direction, thus providing necessary water to the flood plain around the Tonle Sap Lake. During the 2011 floods, Kompong Pluk suffered but was able to cope with the "unnatural" levels of flooding with better flexibility than many surrounding communities. I also was moved by the community's deep connection to Neak Ta, the omnipresent natural spirit that allows harmonious living with the river and forest. My installation reflects both the simple modular structure of their homes and the humble constructions of the spirit houses. Here the sound-scape of the river-scape at Kompong Pluk can be heard – layers of sounds from people's everyday lives with the water, fishing, storytelling and ceremonial practices for the river spirits.

Working primarily with photograph and sound, Vuth Lyno, born in Phnom Penh, 1982, is interested in ideas around social transformation and national progress in Cambodia. He obtained a Bachelor's degree in Information Technology in 2002 as well as a Master's degree in Social Science in 2009 at the RMIT University, Australia. He is a founding member of the artist collective Stiev Selapak / Art Rebels and director of Sa Sa Art Projects, Phnom Penh. He has organized numerous exhibitions and evens in Cambodia, most recently *The Sounding Room* in collaboration with Incidental, UK. His group exhibitions include *14+1* (2007) and *Blue Angels* (2008), both of which were held at the French Cultural Center Galley, Phnom Penh, and the solo exhibition *Thoamada* (SA SA BASSAC, 2011).



# ស-សបាសាក់ SA SA BASSAC

#18 2nd Floor, Sothearos Boulevard
Phnom Penh, Kingdom of Cambodia

Open Thu-Fri 2pm-6pm, Sat-Sun 10am-6pm
and by appointment
+855 (0)17 774 864, info@sasabassac.com
www.sasabassac.com

បកប្រែជាភាសាខ្មែរដោយ ស៊ុំ ស៊ីថែន និង វុធ លីណូ
Khmer translation by Sum Sithen and Vuth Lyno

ពិព័រណ៍ទិដ្ឋភាពទន្លេនៅក្នុងការផ្លាស់ប្តូរ ប្រចាំនៅទីក្រុងភ្នំពេញ ត្រូវបានគាំទ្រដោយ
Riverscapes IN FLUX Phnom Penh is supported by

River Scapes IN FLUX | GOETHE INSTITUT | META HOUSE PHNOM PENH | INSTITUT FRANÇAIS CAMBODGE

កំណត់សម្គាល់ NOTES

# កំណត់សម្គាល់ NOTES

blog.goethe.de/riverscapes